# ស្ថិតិ និងតារាង តុល្យការថាមពល ២០២០-២០២១



រៀបចំដោយអគ្គនាយកដ្ឋានថាមពល
គាំទ្រដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

២០២៣

# បុព្វកថា

វិស័យថាមពលគឺជាផ្នែកមួយដ៏សំខាន់បំផុតនៃសង្គមសម័យទំនើប ដែលគាំទ្រដល់កំណើនសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងនិរន្តរភាពបរិស្ថាន។ ការយល់ដឹង និងការវិភាគលើនិន្នាការ និងថាមវន្តថាមពលគឺចាំបាច់សម្រាប់ការជូនដំណឹងអំពីការសម្រេចចិត្តគោលនយោបាយ ការវិនិយោគ និងយុទ្ធសាស្ត្រសម្រាប់អនាគតថាមពលប្រកបដោយសុវត្ថិភាព និងនិរន្តរភាព។ នៅក្នុងសម័យទំនើបភាវូបនីយកម្មនេះ តម្រូវការថាមពលមានកំណើនកាន់តែខ្លាំងឡើងក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម លំនៅដ្ឋាន និងមធ្យោបាយដឹកជញ្ជូន។ ការកើនឡើងនៃកត្តាទាំងនេះ បានធ្វើឱ្យឥន្ធនៈថាមពលក្លាយជាទំនិញពាណិជ្ជកម្មខ្លាំងបំផុតនៅលើទីផ្សារសកល។ ដោយសារឥន្ធនៈហ្វូស៊ីល ដូចជា ធ្យូងថ្ម ប្រេង និងឧស្ម័នធម្មជាតិ ជាប្រភពធនធានមានកំណត់ ឯការប្រើប្រាស់មានការកើនឡើង ដូចនេះ យើងត្រូវតាមដាន និងគ្រប់គ្រងធនធានទាំងអស់នេះប្រកបដោយចីរភាព ដើម្បីធានាឯករាជ្យភាព សន្តិសុខ និងប្រសិទ្ធភាពថាមពល ក្នុងក្របខ័ណ្ឌនៃការកាត់បន្ថយផលប៉ះពាល់បរិស្ថានជាអតិបរមា និងចូលរួមទប់ស្កាត់ការប្រែប្រួលអាកាសធាតុ។ ការប្រមូល និងគ្រប់គ្រងទិន្នន័យផលិតកម្មនិងការប្រើប្រាស់ថាមពលគឺជាការបញ្ជាក់អំពីភាពច្បាស់លាស់នៃស្ថានភាពថាមពលនៅក្នុងប្រទេសនីមួយៗ។ ដើម្បីចងក្រងទិន្នន័យឱ្យមានលក្ខណៈគ្រប់គ្រាន់ នោះតម្រូវឱ្យមានយន្តការច្បាស់លាស់ដោយផ្អែកលើការកត់ត្រាត្រឹមត្រូវ នីតិវិធី វិធីសាស្ត្រ ការវិភាគ ការគ្រប់គ្រងច្បាស់លាស់ និងមានធនធានគ្រប់គ្រាន់។

បច្ចុប្បន្នការខិតខំប្រឹងប្រែងរបស់កម្ពុជាលើការងារអន្តរកាលថាមពល ក៏គូសបញ្ជាក់ពីសារៈសំខាន់នៃស្ថិតិថាមពលក្នុងដំណើរការអភិវឌ្ឍវិស័យថាមពល។ ថាមពលមិនគ្រាន់តែជាអគ្គិសនីដែលប្រើប្រាស់ក្នុងបរិក្ខារអេឡិចត្រូនិកប៉ុណ្ណោះទេ តែវាជាមធ្យោបាយមួយដែលអាចផ្តល់អំណាចដល់បុគ្គល គ្រួសារ និងប្រទេសទាំងមូលនូវលទ្ធភាពដើម្បីបញ្ចេញសក្តានុពលរបស់ពួកគេ។ វាជាធាតុចូលយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍធនធានមនុស្ស

សក្តានុពលរបស់ពួកគេ។ វាជាធាតុចូលយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍធនធានមនុស្ស មិនត្រឹមតែក្នុងជំនាន់នេះទេ ថែមទាំងជំនាន់ក្រោយៗទៀត។ ដោយសារកត្តាសន្តិភាព និងស្ថិរភាពនយោបាយ ទើបការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថានក្នុងទសវត្សរ៍ចុងក្រោយនេះ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាគួរជាទីកត់សម្គាល់។

ដើម្បីឆ្លើយតបទៅនឹងកំណើននៃតម្រូវការថាមពលនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅជាយុទ្ធសាស្ត្រថាមពលជាតិសំខាន់ៗដែលធ្លាប់បានអនុវត្តក្នុងអាណត្តិកន្លងមកហើយរួមមាន៖ ១-ជំរុញការអភិវឌ្ឍមូលដ្ឋានគ្រឹះនៃប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដើម្បីផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់និងក្នុងតម្លៃសមរម្យដល់សេចក្តីត្រូវការប្រើប្រាស់គ្រប់ប្រភេទ ២-ជំរុញការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងបង្កើនសុខដុមនីយភាពនៃការរស់នៅរបស់ប្រជាជននៅតំបន់ជនបទ ៣-ការចូលរួមវិនិយោគដោយឯកជនក្នុងការអភិវឌ្ឍវិស័យថាមពល និងកាត់បន្ថយការប៉ះពាល់បរិស្ថានធម្មជាតិនិងសង្គម ៤-ជំរុញបង្កើនប្រសិទ្ធភាពនិងសុវត្ថិភាពនៃការធ្វើសេវាកម្មអគ្គិសនី និង៥-ចូលរួមអភិវឌ្ឍប្រភពថាមពលស្អាត។ ទិន្នន័យស្ថិតិថាមពល អំពីបរិមាណនៃការផ្គត់ផ្គង់ និងការប្រើប្រាស់ប្រចាំឆ្នាំ ក្នុងវិស័យនានាគឺជាធាតុចូលដ៏សំខាន់សម្រាប់ធានាឱ្យបាននូវការផ្គត់ផ្គង់ និងការប្រើប្រាស់ថាមពលប្រកបដោយនិរន្តរភាព ស្ថេរភាព និងសុវត្ថិភាព និងជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពថាមពលជាតិ និងសម្រាប់រៀបចំតារាងតុល្យការជាតិថាមពល និងការព្យាករណ៍តម្រូវការថាមពលសម្រាប់ពេលអនាគត។ ដើម្បីធានាគុណភាព និងសុក្រឹតភាពទិន្នន័យស្ថិតិថាមពល ការរៀបចំចងក្រងប្រព័ន្ធប្រមូលទិន្នន័យថាមពល ក្រសួងរ៉ែ និងថាមពលបានបង្កើតក្រុមការងារអន្តរស្ថាប័ន ដែលដឹកនាំដោយឯកឧត្តមបណ្ឌិត **ទី នរិន្ទ** រដ្ឋលេខាធិការប្រចាំការក្រសួងរ៉ែ និងថាមពល ដើម្បីរៀបចំប្រមូលទិន្នន័យពាក់ព័ន្ធតាមវិស័យនីមួយៗ ការធ្វើបច្ចុប្បន្នភាព និងការរៀបចំ

របាយការណ៍នេះត្រូវបានរៀបចំជាភាសាជាតិលើកទី១ ផ្តោតសំខាន់ទៅលើមូលដ្ឋានគ្រឹះថាមពល (ឥន្ធនៈហ្វូសស៊ីល និងថាមពលកកើតឡើងវិញ) ទិន្នន័យនៃការផ្គត់ផ្គង់ និងការប្រើប្រាស់ថាមពល និងតារាងតុល្យការថាមពល និងក៏មានភ្ជាប់តារាងឧបសម្ព័ន្ធ នូវកម្រងសំណួរសម្រាប់ក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន ប្រើក្នុងការប្រមូលទិន្នន័យ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍ឧបទេសស្ថិតិស្ថិតិនិងតារាងតុល្យការថាមពលនេះនឹងបានជាវិជ្ជាសម្បត្តិយ៉ាងសំខាន់មួយសម្រាប់អ្នកត្រូវការ និងអ្នកពាក់ព័ន្ធទាំងអស់ប្រើប្រាស់ជាភ័តានុភ័តតាមសេចក្តីត្រូវការ។

ជាទីបញ្ចប់ តាំងនាមឱ្យក្រសួងរ៉ែ និងថាមពល ខ្ញុំសូមសម្តែងកតញ្ញូតាដឹងគុណចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំរបស់ក្រុមការងារបច្ចេកទេស ដែលបានរៀបចំចងក្រង និងបោះពុម្ពផ្សព្វផ្សាយរបាយការណ៍ស្តីពី "ស្ថិតិនិងតារាងតុល្យការថាមពលឆ្នាំ២០២០-២០២១" នេះ និងសូមថ្លែងអំណរគុណដល់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដែលបានផ្តល់ការគាំទ្រ និងជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់ជាមួយក្រសួងរ៉ែ និងថាមពល។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កែវ រតនៈ**

# **គុណានុមោទនា**

របាយការណ៍ស្ដីពី “ស្ថិតិនិងតារាងតុល្យការថាមពលឆ្នាំ២០២០-២០២១” ជាឯកសារដ៏មានសារៈសំខាន់មួយ សម្រាប់ផ្ដល់ចំណេះដឹងមូលដ្ឋានក្នុងវិស័យថាមពល។ វណ្ណកម្មដ៏មានតម្លៃនេះ លេចជារូបរាងឡើងបានក្រោមការគាំទ្រពីឯកឧត្តម **ស៊ុយ សែម** អតីតរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ដែលឯកឧត្តមតែងតែយកចិត្តទុកដាក់ចំពោះការកសាងសមត្ថភាពរបស់មន្ត្រី និងការបង្កើតស្នាដៃផ្សេងៗ ដើម្បីជាប្រយោជន៍ក្នុងការបង្កើនពុទ្ធិ និងជំនាញបច្ចេកទេស និងដឹកនាំសម្របសម្រួលដោយ **ឯកឧត្តម ហេង គុណលាង** អគ្គនាយក នៃអគ្គនាយកដ្ឋានថាមពលក្រសួងរ៉ែ និងថាមពល ដើម្បីឱ្យការរៀបចំប្រមូលទិន្នន័យពាក់ព័ន្ធតាមវិស័យនីមួយៗ ការធ្វើបច្ចុប្បន្នភាព និងការរៀបចំរបាយការណ៍ “ស្ថិតិនិងតារាងតុល្យការថាមពលឆ្នាំ២០២០-២០២១” ស្របតាមស្ដង់ដា IEA ( International Energy Agency) ។

គុណូបការៈដ៏ធំធេងមួយចំណែកទៀត ចំពោះការរៀបចំ ចងក្រង បោះពុម្ព និងធ្វើសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍នេះ ដំណើរការដោយរលូន ដោយសារមានការគាំទ្រថវិកាពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ។

ខ្ញុំសូមអរគុណជាអតិបរមា ចំពោះក្រុមការងារបច្ចេកទេស នៃនាយកដ្ឋានអភិវឌ្ឍថាមពល ទីប្រឹក្សាគម្រោង UNDP និងក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន ដែលបានចូលរួមសហការផ្ដល់ទិន្នន័យពាក់ព័ន្ធតាមវិស័យនីមួយៗ និងបានរៀបចំចងក្រងជាសៀវភៅរបាយការណ៍ “ស្ថិតិនិងតារាងតុល្យការថាមពលឆ្នាំ២០២០-២០២១” លេចចេញជារូបរាងតាមការគ្រោងទុក និងសូមឱ្យតថ្លមនុញ្ញផលដែលកើតចេញពីបុញ្ញកម្មនេះ ឱ្យផលជាភាពចម្រុងចម្រើនក្នុងវិជ្ជាជីវៈរបស់ខ្លួនប្រកបដោយភិយ្យោភាពតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៩កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០២៣

**រដ្ឋលេខាធិការប្រចាំការ**
**និងជាប្រធានក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន**

**បណ្ឌិត ទី នរិន្ទ**

# ខ្លឹមសារសង្ខេប

ដោយមានកិច្ចសហការគាំទ្ររបស់ “កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ” និងកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន អស់រយៈពេលប្រមាណមួយឆ្នាំ ក្រសួងរ៉ែ និងថាមពល មានមោទនភាព សូមបង្ហាញជូននូវរបាយការណ៍ស្តីពីស្ថិតិ និងតារាងតុល្យការថាមពលសម្រាប់ឆ្នាំ២០២០-២០២១ ដែលចេញផ្សាយក្នុងឆ្នាំ២០២៣ នេះ ដែលមានខ្លឹមសារសង្ខេបដូចតទៅ៖

១.១ ការផ្គត់ផ្គង់ថាមពលសរុប ក្នុងឆ្នាំ២០២០ មានចំនួន ៧ ៥៧១ ktoe រួមមាន៖

- ៤២,៧៦% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីប្រេងឥន្ធនៈ និងឧស្ម័ន (១.ឧស្ម័ន LPG ២.ប្រេងសាំង ៣.ប្រេងយន្តហោះ ៤.ប្រេងម៉ាស៊ូត ៥.ប្រេងខ្មៅ ៦.ប្រេងរំអិល ៧.កៅស៊ូក្រាលថ្នល់ ៨.សារធាតុបន្ថែម MTBE)
- ២៧,១៨% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីធ្យូងថ្ម (ធ្យូងថ្មនាំចូល និងធ្យូងថ្មក្នុងស្រុក)
- ២០,៦៨% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីជីវម៉ាស (អុស ធ្យូង កាកអំពៅ និងជីវឧស្ម័ន)
- ៤,៤៥% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីវារីអគ្គិសនី (អានុភាពសរុប ១ ៣២៩,៧ មេហ្គាវ៉ាត់)
- ០,៣១% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីថាមពលពន្លឺព្រះអាទិត្យ (អានុភាពសរុប ២៩៦,៨ មេហ្គាវ៉ាត់)
- ៤,៣៣% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីការនាំចូលអគ្គិសនីពីប្រទេសជិតខាង (ប្រទេសថៃ វៀតណាម ឡាវ)

១.២ ការប្រើប្រាស់ថាមពលសរុប ក្នុងឆ្នាំ២០២០ មានចំនួន ៦ ៣៩៨ ktoe រួមមាន៖

- ៣៦,០៣% នៃថាមពលសរុប ប្រើប្រាស់ក្នុងវិស័យដឹកជញ្ជូន

- ៣៥,៥១% នៃថាមពលសរុប ប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម
- ១៦,៣៥% នៃថាមពលសរុប ប្រើប្រាស់ក្នុងវិស័យលំនៅដ្ឋាន
- ៦,៦១% នៃថាមពលសរុប ប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម និងសេវាកម្ម (អគារពាណិជ្ជកម្ម អគារសាធារណៈ សណ្ឋាគារ ផ្សារ ផ្សារទំនើប ភោជនីយដ្ឋាន មន្ទីរពេទ្យ និងសាលារៀន)
- ៣,៤៦% នៃថាមពលសរុប ប្រើប្រាស់ក្នុងវិស័យកសិកម្ម និងនេសាទ
- ២,០៥% នៃថាមពលសរុប ប្រើប្រាស់ក្នុងទម្រង់ដែលមិនបំប្លែងជាថាមពល (ប្រេងម៉ាស៊ីន និងកៅស៊ូក្រាលថ្នល់)

១.៣ ការផ្គត់ផ្គង់ថាមពលសរុប ក្នុងឆ្នាំ២០២១ មានចំនួន ៧ ៥៧៣ ktoe រួមមាន៖

- ៤២,៨៤% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីប្រេងឥន្ធនៈ និងឧស្ម័ន (១.ឧស្ម័ន LPG ២.ប្រេងសាំង ៣.ប្រេងយន្តហោះ ៤.ប្រេងម៉ាស៊ូត ៥.ប្រេងខ្មៅ ៦.ប្រេងរំអិល ៧.កៅស៊ូក្រាល់ថ្នល់ ៨.សារធាតុបន្ថែម methyl tertiary butyl ether (MTBE)
- ១៨,៣២% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីធ្យូងថ្ម (ធ្យូងថ្មនាំចូល និងធ្យូងថ្មក្នុងស្រុក)
- ២៨,២២% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីជីវម៉ាស (អុស ធ្យូង កាកអំពៅ និងជីវឧស្ម័ន)
- ៥,៨០% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីវារីអគ្គិសនី (អានុភាពសរុប ១ ៣២៩,៧ មេហ្គាវ៉ាត់)
- ០,៧០% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីថាមពលពន្លឺព្រះអាទិត្យ (អានុភាពសរុប ២៩៦,៨ មេហ្គាវ៉ាត់)
- ៣,៨៤% នៃការផ្គត់ផ្គង់ថាមពលមានប្រភពមកពីការនាំចូលអគ្គិសនីពីប្រទេសជិតខាង (ប្រទេសថៃ វៀតណាម ឡាវ)

១.៤ ការប្រើប្រាស់ថាមពលសរុប ក្នុងឆ្នាំ២០២១ មានចំនួន ៦ ៦៥៦ ktoe រួមមាន៖

- ៣៣,៤៧% នៃថាមពលសរុប ប្រើប្រាស់ក្នុងវិស័យដឹកជញ្ជូន

- ៣៧,១៩% នៃថាមពលសរុប ប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម
- ១៧,៣៧% នៃថាមពលសរុប ប្រើប្រាស់ក្នុងវិស័យលំនៅដ្ឋាន
- ៦,២២% នៃថាមពលសរុប ប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម និងសេវាកម្ម (អគារពាណិជ្ជកម្ម អគារសាធារណៈ សណ្ឋាគារ ផ្សារ ផ្សារទំនើប ភោជនីយដ្ឋាន មន្ទីរពេទ្យ និងសាលារៀន)
- ៣,៥១% នៃថាមពលសរុប ប្រើប្រាស់ក្នុងវិស័យកសិកម្ម និងនេសាទ
- ២,៥២% នៃថាមពលសរុប ប្រើប្រាស់ក្នុងទម្រង់ដែលមិនបំប្លែងជាថាមពល (ប្រេងម៉ាស៊ីន និងកៅស៊ូក្រាលថ្នល់)

# ប្រកាសស្ដីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន ប្រមូលទិន្នន័យនិងរៀបចំ "ស្ថិតិនិងតារាងតុល្យការថាមពលកម្ពុជាប្រចាំឆ្នាំ"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០២៥៥ រថ.អថ.ប្រក

## ប្រកាស
## ស្ដីពី
## ការបង្កើតក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន ប្រមូលទិន្នន័យនិងរៀបចំ "ស្ថិតិនិងតារាងតុល្យការថាមពលកម្ពុជាប្រចាំឆ្នាំ"

## ក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ ០៣២១ រថ.អថ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានថាមពល
- បានឃើញលិខិតលេខ ២៩០៥/២២ អ គ រ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- បានឃើញលិខិតលេខ ២៩៩៨ ជនស/អរប/បុ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញលិខិតលេខ ៤១៩ សជណ.វជទ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ របស់ក្រសួងទេសចរណ៍
- បានឃើញលិខិតលេខ ១៦៦៤.លទ.២២ អអក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

- បានឃើញលិខិតលេខ ៣១៩០ ព.ណ.ន.ច ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញលិខិតលេខ ២២៨៥ ឧវបន.បល ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញលិខិតលេខ ២០៤០ សជណ ប.ស្ត ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ក្រសួងបរិស្ថាន
- បានឃើញលិខិតលេខ ១០២៤៣/៦៥៣ កសក.នផ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

**<u>សម្រេច</u>**

**ប្រការ ១**

បង្កើតក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន សម្រាប់ប្រមូលទិន្នន័យនិងរៀបចំ "ស្ថិតិនិងតារាងតុល្យការថាមពលកម្ពុជាប្រចាំឆ្នាំ" ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | **បណ្ឌិត ទី នរិទ្ធ** | រដ្ឋលេខាធិការ | MME | ប្រធាន |
| ២-ឯកឧត្តម | **ហេង គុណលាង** | អគ្គនាយកថាមពល | MME | អនុប្រធាន |
| ៣-ឯកឧត្តម | **ជួរ ជេតទីវន្ត** | ទីប្រឹក្សាក្រសួងនិងជាអគ្គនាយករង | MISTI | សមាជិក |
| ៤-ឯកឧត្តម | **គង់ សុភារក្ស** | ទីប្រឹក្សាក្រសួងនិងជាប្រធាននាយកដ្ឋាន | MOT | សមាជិក |
| ៥-លោក | **ពាំង ប៉ារ៉ុល** | ប្រធាននាយកដ្ឋានអភិវឌ្ឍថាមពល | MME | សមាជិក |
| ៦-លោក | **ហ៊ិន សាង** | ប្រធាននាយកដ្ឋានផែនការស្ថិតិ | MISTI | សមាជិក |
| ៧-លោក | **ជៀវ វីន** | ប្រធាននាយកដ្ឋានសុវត្ថិភាពអាកាសយានដ្ឋាន | SSCA | សមាជិក |
| ៨-លោក | **សុខ ច័ន្ទដារ៉េត** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍថាមពល | MME | សមាជិក |
| ៩-លោក | **កែវ វិចិត្រ** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍថាមពល | MME | សមាជិក |
| ១០-លោក | **ឡួន សុផល** | អនុប្រធាននាយកដ្ឋាននាំចេញ នាំចូល | MOC | សមាជិក |
| ១១-លោក | **ឈឹម សុភ័ក្ត្រ** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន | MOC | សមាជិក |
| ១២-លោក | **ទី សឿន** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច | MLMUPC | សមាជិក |
| ១៣-លោក | **ស្វ តូនៃ** | អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច | NIS | សមាជិក |
| ១៤-លោក | **ឃឹម សុភត្រា** | អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច | NIS | សមាជិក |
| ១៥-លោក | **អ៊ិន ប៊ុនថា** | ប្រធានការិយាល័យ | MLMUPC | សមាជិក |
| ១៦-លោក | **ម៉ែន សុទ្ធី** | ប្រធានការិយាល័យស្ថិតិ | MAFF | សមាជិក |
| ១៧-លោក | **សៅធុំ ពិសិដ្ឋ** | ប្រធានការិយាល័យ | MOE | សមាជិក |
| ១៨-លោក | **ប៊ូ សុធារិទ្ធ** | ប្រធានការិយាល័យគោលនយោបាយ | GDCE | សមាជិក |
| ១៩-លោក | **ទឹម ឧត្តម** | ប្រធានការិយាល័យចុះបញ្ជីយានយន្ត | MPWT | សមាជិក |

| | | | | |
|---|---|---|---|---|
| ២០-លោក | **ស៊ី លីហួ** | ប្រធានការិយាល័យស្ថិតិនិងព័ត៌មានដឹកជញ្ជូន | MPWT | សមាជិក |
| ២១-លោក | **ម៉ិច សុឃីម** | អនុប្រធានការិយាល័យ | MOE | សមាជិក |
| ២២-លោក | **ម៉ិត មរកត** | អនុប្រធានការិយាល័យស្ថិតិ | MAFF | សមាជិក |
| ២៣-លោក | **ទ្រិច ភារូឌីន** | អនុប្រធានការិយាល័យផែនការ | EDC | សមាជិក |
| ២៤-លោក | **ផន សៅម៉ាលិ** | ប្រធានផ្នែកត្រួតពិនិត្យសេវាកម្ម | EAC | សមាជិក |
| ២៥-លោក | **អេខ ទីឃូរ៉ា** | ប្រធានផ្នែកបទប្បញ្ញត្តិ និងអាជ្ញាបណ្ណ | EAC | សមាជិក |
| ២៦-លោក | **ម៉ៅ មុណា** | អនុប្រធានផ្នែកនៃការិយាល័យផែនការ | EDC | សមាជិក |
| ២៧-លោក | **ហោ ស៊ីណាត** | មន្ត្រីនៃនាយកដ្ឋានរដ្ឋាករ | GDCE | សមាជិក |
| ២៨-លោក | **ឡេខ ធារិទ្ធរ័ត្តនា** | មន្ត្រីនៃនាយកដ្ឋានស្ថិតិទេសចរណ៍ | MOT | សមាជិក |

**ប្រការ ២**

ក្រុមការងារដែលបានបង្កើតក្នុងប្រការ ១ ខាងលើ មានភារកិច្ចដូចតទៅ៖

- សហការប្រមូលទិន្នន័យពាក់ព័ន្ធតាមវិស័យនីមួយៗ ដើម្បីប្រមូលផ្តុំរៀបចំជាស្ថិតិថាមពល
- ធ្វើការសិក្សារួមគ្នា ដើម្បីព្យាករណ៍តម្រូវការថាមពលសរុបតាមឆ្នាំនីមួយៗ
- ពិនិត្យឯកសារពាក់ព័ន្ធជាមួយវិស័យថាមពល រៀបចំធ្វើបច្ចុប្បន្នភាពស្ថិតិថាមពល រៀបចំផែនការសកម្មភាពសម្រាប់វិស័យថាមពលដើម្បីធានាឱ្យបាននូវការផ្គត់ផ្គង់និងការប្រើប្រាស់ថាមពលនាពេលអនាគតប្រកបដោយនិរន្តរភាព ស្ថិរភាព សុវត្ថិភាពដល់វិស័យពាក់ព័ន្ធនិងអ្នកប្រើប្រាស់ទាំងថ្នាក់ជាតិ តំបន់ និងអន្តរជាតិ សម្រាប់ធ្វើការអភិវឌ្ឍវិស័យថាមពលឆ្នាំ២០២០-២០២១ និងជារៀងរាល់ឆ្នាំបន្តបន្ទាប់ទៅមុខទៀត។
- រៀបចំតារាងតុល្យការថាមពល ដើម្បីវិភាគលំហូរទិន្នន័យនៃការផ្គត់ផ្គង់ ការបំប្លែង និងតម្រូវការថាមពលតាមប្រភេទឥន្ធនៈ និងសកម្មភាពសេដ្ឋកិច្ចក្នុងទម្រង់ដែលអាចផ្ទៀងផ្ទាត់និងយកទៅប្រើប្រាស់បាន សម្រាប់បង្កើតសូចនាករសំខាន់ៗដើម្បីវាស់វែងឬតាមដាន វាយតម្លៃអំពីវឌ្ឍនភាពនៃគោលនយោបាយ និងផែនការសម្រាប់វិស័យថាមពល ឬវិស័យដែលពាក់ព័ន្ធសម្រាប់ធ្វើការអភិវឌ្ឍវិស័យថាមពលប្រចាំឆ្នាំ។
- សហការជាមួយក្រុមហ៊ុនពិគ្រោះយោបល់ ឬទីប្រឹក្សាពិគ្រោះយោបល់ ក្នុងការសិក្សានិងរៀបចំធ្វើបច្ចុប្បន្នភាពស្ថិតិនិងតារាងតុល្យការថាមពល របស់ព្រះរាជាណាចក្រកម្ពុជា។
- រៀបចំលទ្ធផលនៃការរៀបចំ "ស្ថិតិនិងតារាងតុល្យការថាមពល" ដើម្បីដាក់ជូន **ឯកឧត្តមរដ្ឋមន្ត្រី** ពិនិត្យសម្រេច។ បន្ទាប់ពីទទួលបានការសម្រេចពី **ឯកឧត្តមរដ្ឋមន្ត្រី** ក្រុមការងារនឹងរៀបចំចងក្រង បោះពុម្ពនិងធ្វើសិក្ខាសាលាផ្សព្វផ្សាយ។

**ប្រការ ៣**

ប្រធានក្រុមការងារបច្ចេកទេសមានសិទ្ធិចុះហត្ថលេខា លើលិខិតអញ្ជើញសមាជិកក្រុមការងារនិងអ្នកពាក់ព័ន្ធដើម្បីធ្វើការប្រជុំពិភាក្សាតាមការចាំបាច់ ហើយសមាជិកទាំងអស់ និងអ្នកពាក់ព័ន្ធ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

**ប្រការ ៤**

ប្រធានក្រុមការងារបច្ចេកទេស អាចស្នើសុំមន្ត្រីជំនាញទទួលបន្ទុកទិន្នន័យ ព័ត៌មាន និងស្ថិតិ របស់ក្រសួង ស្ថាប័ននីមួយៗបន្ថែម ដើម្បីជួយបំពេញការងាររបស់ខ្លួន តាមការចំបាច់។

**ប្រការ ៥**

ឯកឧត្តម អស់លោក និងសាមីខ្លួន ដែលមានឈ្មោះដូចមានចែងក្នុងប្រការ ១ ខាងលើ មានភារកិច្ចអនុវត្ត តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨ កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

ស៊ុយ សែម

**ចម្លងជូនៈ**

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គិសនីកម្ពុជា
- វិទ្យាស្ថានជាតិស្ថិតិ "ដើម្បីជូនជ្រាប"
- សាមីជន ដូចមានឈ្មោះក្នុងប្រការ ១ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# មាតិកា

**បុព្វកថា** ---------------------------------------------------------------------------- I
**គុណកថា** ---------------------------------------------------------------------------- IV
**ខ្លឹមសារសង្ខេប** ---------------------------------------------------------------------------- V
**ប្រកាសស្តីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន ប្រមូលទិន្នន័យនិងរៀបចំស្ថិតិនិងតារាងតុល្យការថាមពលកម្ពុជាប្រចាំឆ្នាំ** ---------------------------- VIII
**បញ្ជីតារាង** ---------------------------------------------------------------------------- XV
**បញ្ជីក្រាហ្វិក** ---------------------------------------------------------------------------- XVI
**ជំពូកទី១៖ សេចក្តីផ្តើម** ---------------------------------------------------------------------------- 1
**ជំពូកទី២៖ ទិន្នន័យថាមពលបឋមចុងក្រោយ** ---------------------------------------- 4
២.១. ធ្យូងថ្ម ---------------------------------------------------------------------------- 4
២.២. ប្រេងឥន្ធនៈ ---------------------------------------------------------------------------- 5
២.២.១. ការផ្គត់ផ្គង់ប្រេងឥន្ធនៈ ---------------------------------------------------------- 5
២.២.២. ការប្រើប្រាស់ប្រេងឥន្ធនៈ ---------------------------------------------------- 7
២.៣. ជីវម៉ាស ---------------------------------------------------------------------------- 9
២.៤. អគ្គិសនី ---------------------------------------------------------------------------- 10
២.៤.១. ផលិតកម្មអគ្គិសនី ---------------------------------------------------------- 10
២.៤.២. ការផ្គត់ផ្គង់អគ្គិសនី ---------------------------------------------------------- 11
២.៤.៣. ការប្រើប្រាស់អគ្គិសនី ---------------------------------------------------------- 12
**ជំពូកទី៣៖ វិភាគការផ្គត់ផ្គង់ និងការប្រើប្រាស់ថាមពល** -------------------------- 14
៣.១. ការផ្គត់ផ្គង់ថាមពលតាមប្រភេទឥន្ធនៈ ------------------------------------ 14

៣.២. ល្បាយនៃការផ្គត់ផ្គង់ថាមពលសរុបតាមប្រភេទឥន្ធនៈ --------------------15
៣.២.១. ល្បាយថាមពលផ្គត់ផ្គង់ក្នុងឆ្នាំ២០២០------------------------------------15
៣.២.២. ល្បាយថាមពលផ្គត់ផ្គង់ក្នុងឆ្នាំ២០២១------------------------------------16
៣.៣. ការប្រើប្រាស់ថាមពលសរុបតាមវិស័យ ---------------------------------------17
៣.៤. ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមវិស័យ --------------------------19
៣.៤.១. ល្បាយប្រើប្រាស់ថាមពលក្នុងឆ្នាំ២០២០ ---------------------------------19
៣.៤.២. ល្បាយប្រើប្រាស់ថាមពលក្នុងឆ្នាំ២០២១------------------------------- 20
៣.៥. ការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ធនៈ ---------------------------- 20
៣.៦. ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ធនៈ---------------- 22
៣.៦.១. សម្រាប់ឆ្នាំ២០២០------------------------------------------------------- 22
៣.៦.២. សម្រាប់ឆ្នាំ២០២១------------------------------------------------------- 23
៣.៧. ការប្រើប្រាស់ធ្យូងថ្ម--------------------------------------------------------- 24
៣.៨. ការប្រើប្រាស់ប្រេងឥន្ធនៈ----------------------------------------------------- 25
៣.៩. ការប្រើប្រាស់ជីវម៉ាស -------------------------------------------------------- 26
**ជំពូកទី ៤៖ ការផលិត និងការប្រើប្រាស់អគ្គិសនី**---------------------------------- 28
៤.១. ការប្រើប្រាស់អគ្គិសនីតាមវិស័យ ------------------------------------------- 29
**ជំពូកទី ៥៖ តារាងតុល្យភាពថាមពល**-------------------------------------------------31
៥.១. ការរៀបចំតារាងតុល្យភាពថាមពល -------------------------------------------31
៥.២-គោលការណ៍គ្រឹះនៃតារាងតុល្យភាពថាមពល -------------------------------31
៥.៣. វិធីសាស្រ្តគណនា ------------------------------------------------------------ 34
៥.៣.១. កម្រងសំណួរថាមពល ------------------------------------------------------ 35
៥.៣.២. ខ្នាត និងការបំប្លែង ------------------------------------------------------- 35

**ជំពូកទី ៦៖ សេចក្ដីសន្និដ្ឋាន និងទិសដៅបន្ត** ---------------------------------- 38
៦.១. សេចក្ដីសន្និដ្ឋាន------------------------------------------------------- 38
៦.២. ទិសដៅបន្ត----------------------------------------------------------- 38
ឧបសម្ព័ន្ធទី ១៖ តារាងតុល្យភាពថាមពលកម្ពុជា ---------------------------- 40
ឧបសម្ព័ន្ធទី ២៖ កម្រងសំណួរប្រមូលទិន្នន័យថាមពល-------------------------41
ឯកសារយោង------------------------------------------------------------- 70

# បញ្ជីតារាង

តារាង២.១ ទិន្នន័យផ្គត់ផ្គង់និងប្រើប្រាស់ធ្យូងថ្ម (គីឡូតោន) ................................. 5
តារាង២.២ ការផ្គត់ផ្គង់ប្រេងឥន្ធនៈ (គីឡូតោន)................................................. 6
តារាង២.៣ ការប្រើប្រាស់ប្រេងឥន្ធនៈតាមវិស័យនីមួយៗ (គីឡូតោន) .................... 8
តារាង២.៤ ទិន្នន័យជីវម៉ាស.......................................................................... 9
តារាង២.៥ ការប្រើប្រាស់ជីវម៉ាស................................................................... 10
តារាង២.៦ ផលិតកម្មអគ្គិសនី (លានគីឡូវ៉ាត់ម៉ោង) ...........................................11
តារាង២.៧ ការផ្គត់ផ្គង់អគ្គិសនី (លានគីឡូវ៉ាត់ម៉ោង) ....................................... 12
តារាង២.៨ ការប្រើប្រាស់អគ្គិសនី (លានគីឡូវ៉ាត់ម៉ោង) ..................................... 13
តារាង ៥.១ មេគុណបំប្លែងផលិតផលថាមពលនៅកម្ពុជា.................................... 37

# បញ្ជីក្រាហ្វិក

ក្រាហ្វិក ៣.១ ការផ្គត់ផ្គង់ថាមពលសរុប ........................................................ 15
ក្រាហ្វិក ៣.២ ល្បាយផ្គត់ផ្គង់ថាមពលសរុបតាមប្រភេទឥន្ធនៈ ឆ្នាំ២០២០ ............ 16
ក្រាហ្វិក ៣.៣ ល្បាយផ្គត់ផ្គង់ថាមពលសរុបតាមប្រភេទឥន្ធនៈ ឆ្នាំ២០២១............. 17
ក្រាហ្វិក ៣.៤ ការប្រើប្រាស់ថាមពលសរុបតាមវិស័យ ....................................... 18
ក្រាហ្វិក ៣.៥ ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមវិស័យឆ្នាំ២០២០............37
ក្រាហ្វិក ៣.៦ ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមវិស័យឆ្នាំ២០២១............20
ក្រាហ្វិក ៣.៧ ការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ធនៈ.............................. 21
ក្រាហ្វិក ៣.៨ ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ធនៈឆ្នាំ២០២០... 22
ក្រាហ្វិក ៣.៩ ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ធនៈឆ្នាំ២០២១... 23
ក្រាហ្វិក ៣.១០ ការប្រើប្រាស់ធ្យូងថ្មឆ្នាំ២០២០-២០២១ .................................. 24
ក្រាហ្វិក ៣.១១ ការប្រើប្រាស់ប្រេងឥន្ធនៈ ..................................................... 25
ក្រាហ្វិក ៣.១២ ការប្រើប្រាស់ជីវម៉ាស ......................................................... 27
ក្រាហ្វិក ៤.១ ការផលិតអគ្គិសនីសរុបតាមប្រភេទឥន្ធនៈ.................................... 29
ក្រាហ្វិក ៤.២ ការប្រើប្រាស់អគ្គិសនីតាមវិស័យ................................................30

# ជំពូក១៖ សេចក្តីផ្តើម

ថាមពលមានតួនាទីយ៉ាងសំខាន់ណាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស សុខុមាលភាព សង្គម និងជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ កាលពីសម័យបុរាណ មនុស្សគ្រប់គ្នាប្រើប្រាស់អុសជាតម្រូវការថាមពលនៅតាមផ្ទះ និងថាមពលខ្យល់ជាកម្លាំងសម្រាប់មធ្យោបាយធ្វើដំណើរតាមសមុទ្រ។ ការកើនឡើងនៃចំនួនមនុស្សរស់នៅតាមកុលសម្ព័ន្ធ និងការបង្កើតឡើងនូវភូមិថ្មី និងក្រុងតូចៗមួយចំនួនបានធ្វើឱ្យអុសក្លាយជាទំនិញដែលមានចលនាសកម្មក្នុងការធ្វើពាណិជ្ជកម្មនៅលើទីផ្សារក្នុងតំបន់។ នៅពេលដែលកត្តាទាំងនេះកើនឡើង តម្រូវការថាមពលក៏កើនឡើងដែរ បណ្តាលឱ្យមានកំណើនការប្រើប្រាស់ធនធានព្រៃឈើ ហើយតំបន់មួយចំនួនបានជួបប្រទះកង្វះខាតអុសសម្រាប់ជាប្រភពថាមពលសម្រាប់ការចម្អិនអាហារ និងការកម្តៅ។ ដោយឡែក ខ្យល់ជាធនធានថាមពលកកើតឡើងវិញ ដូចនេះតម្រូវការថាមពលខ្យល់សម្រាប់ការធ្វើចរាចរណ៍តាមទូកពុំជួបប្រទះកង្វះខាតទេ។ ទន្ទឹមនឹងនេះផងដែរ វិស័យកសិកម្មនៅសម័យបុរាណនៅតែបន្តប្រើប្រាស់កម្លាំងខ្យល់ក្នុងដំណើរការមេកានិកផ្សេងៗ ជាពិសេស ការបូមទឹកសម្រាប់កសិកម្ម និងការកិនគ្រាប់ធញ្ញជាតិដែលជាផលិតផលកសិកម្ម នាសម័យនោះ។

ថាមពល គឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដូចនេះ ប្រសិនបើគ្មានថាមពល នោះការអភិវឌ្ឍសេដ្ឋកិច្ចនឹងមានលក្ខណៈយឺត និងមានកម្រិត។ ក្នុងសម័យសកលភាវូបនីយកម្មនេះ តម្រូវការថាមពលមានកំណើនកាន់តែខ្លាំងឡើងក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម លំនៅដ្ឋាន និងមធ្យោបាយដឹកជញ្ជូន។ ការកើនឡើងនៃកត្តាទាំងនេះបានធ្វើឱ្យថាមពលឥន្ធនៈ ក្លាយជាទំនិញពាណិជ្ជកម្មដ៏មានសក្តានុពលបំផុតនៅលើទីផ្សារសកលលោក។ ដោយសារឥន្ធនៈហ្វូស៊ីល ដូចជា ធ្យូងថ្ម ប្រេង និងឧស្ម័នធម្មជាតិ គឺជាប្រភពធនធានមានកំណត់ និងការប្រើប្រាស់មានការកើនឡើង

យើងត្រូវតាមដាន និងគ្រប់គ្រងធនធានទាំងអស់នេះប្រកបដោយចីរភាព ដើម្បីធានាឯករាជ្យភាព សន្តិភាព សុវត្ថិភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល ក្នុងក្របខ័ណ្ឌនៃការកាត់បន្ថយផលប៉ះពាល់បរិស្ថានជាអតិបរមា និងទប់ស្កាត់ការប្រែប្រួលអាកាសធាតុសកល។

នៅពេលមានការប្រើប្រាស់ថាមពលកាន់តែច្រើនឡើង ការផលិត ការកែច្នៃ ការធ្វើពាណិជ្ជកម្ម ការខាតបង់ ក៏មានការកើនឡើងដែរ ដែលជាកត្តាធ្វើឱ្យមានការកើនឡើងឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស ដែលអាចប៉ះពាល់ដល់សុខមាលភាពរបស់មនុស្សដោយផ្ទាល់តាមរយៈការបង្ករជារោគ និងជំងឺផ្សេងៗ ជាពិសេសជំងឺផ្លូវដង្ហើម និងជំងឺស្បែក។ សម្រាប់ការប៉ះពាល់ដោយប្រយោល គឺឧស្ម័នផ្ទះកញ្ចក់ដែលកើតចេញពីចំហេះឥន្ធនៈ ជាពិសេសឧស្ម័នកាបូនិក បានចូលរួមបង្ករឱ្យមានការកើនឡើងសីតុណ្ហភាពផែនដី ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់លំនឹងឋានប្រព័ន្ធ និងជីវៈចម្រុះនៅលើផែនដី។ ហេតុដូច្នេះហើយ វាជាប្រធានបទសំខាន់ក្នុងរបៀបវារៈអន្តរជាតិ ដែលតម្រូវឱ្យប្រទេសនីមួយៗចូលរួមដោះស្រាយបញ្ហាឱ្យទាន់ពេលវេលា និងធានាបាននូវភាពត្រឹមត្រូវ និងដោយនិរន្តរភាពនៃការប្រើប្រាស់ថាមពល។

ការប្រមូល និងគ្រប់គ្រងទិន្នន័យផលិតកម្ម និងការប្រើប្រាស់ថាមពល គឺជាការបញ្ជាក់អំពីភាពច្បាស់លាស់នៃស្ថានភាពថាមពលនៅក្នុងប្រទេសនីមួយៗ។ ដើម្បីចងក្រងទិន្នន័យឱ្យមានលក្ខណៈគ្រប់គ្រាន់ ទាមទារឱ្យមានយន្តការច្បាស់លាស់ ដោយផ្អែកលើការកត់ត្រាត្រឹមត្រូវ នីតិវិធី វិធីសាស្រ្ត ការវិភាគ ការគ្រប់គ្រងច្បាស់លាស់ និងធនធានគ្រប់គ្រាន់។ ប៉ុន្តែបញ្ហាប្រឈមនៃការរៀបចំស្ថិតិថាមពលប្រកបដោយចីរភាព គឺបណ្តាលមកពីសេរីភាវូបនីយកម្មនៃទីផ្សារថាមពល ការខ្វះខាតថវិកា និងកង្វះខាតមន្ត្រីជំនាញដែលមានសមត្ថភាពគ្រប់គ្រាន់។

ដូច្នេះ ការដោះស្រាយបញ្ហាខាងលើនេះ គួរត្រូវបានធ្វើឱ្យលឿនតាមដែលអាចធ្វើទៅបាន ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដូចជា ១-អ្នករៀបចំគោលនយោបាយថាមពល ចាំបាច់ត្រូវមានទិន្នន័យពាក់ព័ន្ធទាំងអស់ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្ត ២-អ្នកប្រើប្រាស់ទិន្នន័យថាមពល ត្រូវដឹងអំពីគុណភាព និងសារប្រយោជន៍នៃការប្រើប្រាស់ទិន្នន័យទាំងនេះ និង៣-អ្នករៀបចំស្ថិតិថាមពល ត្រូវពង្រឹងសមត្ថភាពនិងរៀបចំប្រព័ន្ធចងក្រង-ប្រមូលទិន្នន័យ ឱ្យមានប្រសិទ្ធិភាព និងសុក្រឹតភាពខ្ពស់ ប្រកបដោយនវានុវត្តន៍ និងឧត្តមានុវត្តអន្តរជាតិថ្មីៗ។

កត្តាទាំងនេះហើយដែលធ្វើឱ្យអគ្គនាយកដ្ឋានថាមពល នៃក្រសួងរ៉ែ និងថាមពល ផ្តួចផ្តើមរៀបចំរបាយការណ៍ស្តីពីស្ថិតិថាមពល និងតារាងតុល្យការថាមពល ប្រចាំឆ្នាំ ២០២០-២០២១ នេះ និងជារៀងរាល់ឆ្នាំបន្តបន្ទាប់ទៅមុខទៀត។

# ជំពូកទី២៖ ទិន្នន័យថាមពលបឋមចុងក្រោយ

ប្រទេសកម្ពុជាប្រើប្រាស់ឥន្ធនៈហ្វូស៊ីលរួមមាន ធ្យូងថ្ម ប្រេង និងឧស្ម័ន ដែលត្រូវបាននាំចូល និងជីវម៉ាសដែលត្រូវបានផលិតក្នុងស្រុក។ ការផលិតថាមពលអគ្គិសនីចេញពីប្រភពវារីអគ្គិសនី ថាមពលពន្លឺព្រះអាទិត្យ ធ្យូងថ្ម និងការនាំចូលថាមពលអគ្គិសនីពីប្រទេសជិតខាង (ថៃ វៀតណាម ឡាវ)។

## ២.១. ធ្យូងថ្ម

ទិន្នន័យធ្យូងថ្មដែលប្រើក្នុងប្រទេសកម្ពុជាបានពីប្រភពធ្យូងថ្មក្នុងស្រុក (ប្រភេទធ្យូងថ្មលីហ្គណាយថ៍) និងធ្យូងថ្មនាំចូល (ប្រភេទធ្យូងថ្មប៊ីទុមីនឹស និងប្រភេទធ្យូងថ្មអនុ-ប៊ីទុមីនឹស)។ ទិន្នន័យធ្យូងថ្មក្នុងស្រុក ត្រូវបានផ្តល់ដោយអគ្គនាយកដ្ឋានធនធានរ៉ែ និងទិន្នន័យធ្យូងថ្មនាំចូល ត្រូវបានផ្តល់ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ ទិន្នន័យការប្រើប្រាស់ធ្យូងថ្ម និងការផ្លាស់ប្តូរស្តុកក្នុងរោងចក្រអគ្គិសនី ត្រូវបានផ្តល់ដោយអគ្គិសនីកម្ពុជា និងរោងចក្រផលិតអគ្គិសនីផ្ទាល់ ចំណែកទិន្នន័យពាក់ព័ន្ធឧស្សាហកម្ម ត្រូវបានផ្តល់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីឱ្យនាយកដ្ឋានអភិវឌ្ឍថាមពល និងទីប្រឹក្សា UNDP ធ្វើការវិភាគ និងគណនាទៅតាមស្ថានភាពកម្ពុជា។ តារាង២.១ បង្ហាញពីទិន្នន័យផ្គត់ផ្គង់និងប្រើប្រាស់ធ្យូងថ្មឆ្នាំ២០២០-២០២១។

តារាង២.១ ទិន្នន័យផ្គត់ផ្គង់ និងប្រើប្រាស់ធ្យូងថ្ម (គីឡូតោន)

| ឆ្នាំ | | ២០២០ | ២០២១ |
|---|---|---|---|
| ការផ្គត់ផ្គង់ | ផលិតក្នុងស្រុក | ១៩,១ | ២៦,៤ |
| | នាំចូល | ៣ ៦០១,៤ | ៣ ១៨២,០ |
| | ផ្លាស់ប្តូរស្តុក | ១១៦,០ | ១២៦,១ |
| | សរុប | ៣ ៥០៤,៥ | ៣ ០៨២,៣ |
| ការប្រើប្រាស់ | ឧស្សាហកម្ម | ៨៥៤,៣ | ១ ០៧៥,៧ |
| | រោងចក្រអគ្គិសនី | ២ ៦៣០,៧ | ១ ៩៧៩,៣ |
| | សរុប | ៣ ៤៨៥,០ | ៣ ០៥៥,០ |

## ២.២. ប្រេងឥន្ធនៈ

### ២.២.១. ការផ្គត់ផ្គង់ប្រេងឥន្ធនៈ

ប្រទេសកម្ពុជាមិនទាន់មានរោងចក្រចម្រាញ់ប្រេងនៅនៅឡើយទេ ដូច្នេះហើយ ប្រេងឥន្ធនៈទាំងអស់ត្រូវបាននាំចូល។ ទិន្នន័យនាំចូលប្រេងឥន្ធនៈ ត្រូវបានផ្តល់ដោយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។ តារាង២.២ បង្ហាញពីទិន្នន័យនាំចូលប្រេងឥន្ធនៈ ឆ្នាំ២០២០-២០២១។

តារាង២.២ ការផ្គត់ផ្គង់ប្រេងឥន្ធនៈ (គីឡូតោន)

| ឆ្នាំ | | ២០២០ | ២០២១ |
|---|---|---|---|
| នាំចូល | ឧស្ម័ន LPG | ៣២២,១ | ៣២៥,៦ |
| | ប្រេងសាំង | ៧៥៨,១ | ៦៩៣,៤ |
| | ប្រេងយន្តហោះ | ៥៩,៧ | ៥០,១ |
| | ប្រេងម៉ាស៊ូត | ១ ៧៧០,៤ | ១ ៧៩២,៧ |
| | ប្រេងខ្មៅ | ១៦៩,៧ | ១៥០,៦ |
| | ប្រេងរំអិល | ១៤,៥ | ១៣,៤ |
| | កៅស៊ូក្រាលថ្នល់ | ១២៥,២ | ១៦៦,០ |
| | សារធាតុបន្ថែម MTBE | ១១,០ | ៣៧,២ |

### ២.២.២. ការប្រើប្រាស់ប្រេងឥន្ធនៈ

ប្រទេសកម្ពុជាប្រើប្រាស់ប្រេងឥន្ធនៈជាច្រើនប្រភេទ (ផលិតផលប្រេង រួមទាំងសារធាតុបន្ថែម) សម្រាប់សកម្មភាពសេដ្ឋកិច្ចផ្សេងៗ (ការដឹកជញ្ជូន ឧស្សាហកម្ម លំនៅដ្ឋាន ពាណិជ្ជកម្ម និងផ្សេងៗទៀត) និងការផលិតអគ្គិសនី។ អគ្គនាយកដ្ឋានប្រេងកាតមានការលំបាកក្នុងការប្រមូលទិន្នន័យសម្រាប់ចែកចាយប្រេងឥន្ធនៈ ពីក្រុមហ៊ុននាំចូល និងចែកចាយ និងដេប៉ូចែកចាយនៅទូទាំងប្រទេសកម្ពុជា។ ដូច្នេះ ការប្រើប្រាស់ប្រេងឥន្ធនៈតាមវិស័យចុងក្រោយនីមួយៗ សម្រាប់ឆ្នាំ២០២០-២០២១ ត្រូវបានផ្តល់ទិន្នន័យដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ (ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ វិទ្យាស្ថានស្ថិតិជាតិនៃក្រសួងផែនការ ក្រសួងទេសចរណ៍ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា) ដើម្បីឱ្យក្រុមការងារបច្ចេកទេសនាយកដ្ឋានអភិវឌ្ឍថាមពល និងទីប្រឹក្សា UNDP ធ្វើការវិភាគ និងគណនាទៅតាមស្ថានភាពជាក់ស្តែងរបស់កម្ពុជា។ តារាង ២.៣ បង្ហាញពីទិន្នន័យការប្រើប្រាស់ប្រេងឥន្ធនៈសម្រាប់វិស័យនីមួយៗតាមប្រភេទ សម្រាប់ឆ្នាំ២០២០-២០២១។

តារាង២.៣ ការប្រើប្រាស់ប្រេងឥន្ធនៈតាមវិស័យនីមួយៗ (គីឡូតោន)

| ឆ្នាំ | | ២០២០ | ២០២១ |
|---|---|---|---|
| ប្រេងសាំង | ផ្លូវគោក | ៦៩៥,៨ | ៦៣៦,៤ |
| សារធាតុបន្ថែម MTBE | | ១១,០ | ៣៧,២ |
| ប្រេងយន្តហោះ | អាកាសយានអន្តរជាតិ | ៥៦,៩ | ៦៥,០ |
| | អាកាសយានក្នុងស្រុក | ២,៨ | ២,១ |
| ឧស្ម័ន LPG | លំនៅដ្ឋាន | ១១៣,៧ | ១៨៥,៦ |
| | ពាណិជ្ជកម្ម | ១៣៣,១ | ១១៣,៣ |
| | ផ្លូវគោក | ៧៤,៨ | ២៦,១ |
| | ឧស្សាហកម្ម | ០,៤ | ០,៦ |
| ប្រេងម៉ាស៊ូត | រោងចក្រអគ្គិសនី | ១៥,៧ | ០ |
| | ឧស្សាហកម្ម | ១៩៣,១ | ២១៧,០ |
| | ផ្លូវគោក | ១ ២៧៧,៦ | ១ ២៩៤,៥ |
| | ផ្លូវដែក | ៣,០ | ៣,៦ |
| | ផ្លូវទឹក | ៦៨,០ | ៦៩,៩ |
| | កសិកម្ម | ១៣៧,៩ | ១៤៣,៩ |
| | នេសាទ | ៧៥,១ | ៦៣,៨ |
| ប្រេងខ្មៅ | រោងចក្រអគ្គិសនី | ៩៨,៦ | ១១៧,០ |
| | ឧស្សាហកម្ម | ១,៩ | ១,៣ |
| | នាវាអន្តរជាតិ | ៦៩,៣ | ៣២,២ |
| ប្រេងរំអិល | ការប្រើប្រាស់មិនមែនថាមពល | ១៤,៥ | ១៣,៤ |
| កៅស៊ូក្រាលថ្នល់ | | ១២៥,២ | ១៦៦,០ |

## ២.៣. ជីវម៉ាស

ប្រភពជីវម៉ាសក្នុងប្រទេសកម្ពុជាមានដូចជាអុសបានពីដំណាំកសិកម្ម និងព្រៃឈើ កាកអំពៅ កាកសំណល់កសិកម្ម និងជីវឧស្ម័នពីលាមកសត្វ។ អុស និងជីវឧស្ម័នត្រូវបានប្រើប្រាស់សម្រាប់ការចម្អិនអាហារនៅតាមលំនៅដ្ឋានតំបន់ជនបទ។ អុសក៏ត្រូវបានប្រើប្រាស់ក្នុងវិស័យឧស្សាហកម្មនិងការផលិតធ្យូងផងដែរ។ ចំណែកធ្យូងអនាម័យត្រូវបានផលិតពីលលាដ៍ដូង និងកម្ទេចឈើ (មិនមានទិន្នន័យ)។ អុស និងកាកអំពៅត្រូវបានប្រើប្រាស់សម្រាប់ផលិតជាអគ្គិសនី។ ដូច្នេះ ការប្រើប្រាស់ជីវម៉ាសសម្រាប់ឆ្នាំ ២០២០-២០២១ ត្រូវបានផ្តល់ទិន្នន័យដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ វិទ្យាស្ថានស្ថិតិជាតិនៃក្រសួងផែនការ អាជ្ញាធរអគ្គិសនីកម្ពុជា និង អគ្គិសនីកម្ពុជា ដើម្បីឱ្យក្រុមការងារបច្ចេកទេសនាយកដ្ឋានអភិវឌ្ឍថាមពល និងទីប្រឹក្សា UNDP ធ្វើការវិភាគ និងគណនាទៅតាមស្ថានភាពនៃប្រទេស។ ការផលិតផលជីវម៉ាស ឆ្នាំ២០២០-២០២១ ត្រូវបានបង្ហាញក្នុងតារាង ២.៤ រីឯការប្រើប្រាស់ជីវម៉ាសឆ្នាំ ២០២០-២០២១ ត្រូវបានបង្ហាញក្នុងតារាង ២.៥។

តារាង២.៤ ទិន្នន័យការផលិតជីវម៉ាស

| ឆ្នាំ | | | ២០២០ | ២០២១ |
|---|---|---|---|---|
| ទិន្នន័យ | អុស | គីឡូតោន | ៥ ៤៩៣,៩ | ៥ ៩៩៨,២ |
| | កាកអំពៅ | គីឡូតោន | ៣៤,៨ | ២៦,០ |
| | ជីវឧស្ម័ន | ម៉ែត្រគូប | ២២,២ | ២២,៦ |
| | ធ្យូង | គីឡូតោន | ៩១,០ | ៩៥,៦ |
| | ធ្យូងអនាម័យ | គីឡូតោន | មិនមាន | មិនមាន |

តារាង២.៥ ទិន្នន័យការប្រើប្រាស់ជីវម៉ាស

| ឆ្នាំ | | | ២០២០ | ២០២១ |
|---|---|---|---|---|
| អុស | លំនៅដ្ឋាន | គីឡូតោន | ១ ៣៧៧,៤ | ១ ៦៤៨,៣ |
| | ឧស្សាហកម្ម | គីឡូតោន | ៣ ៥៤៧,២ | ៣ ៧៥៣,៥ |
| | ផលិតកម្មធ្យូង | គីឡូតោន | ៥៦៣,៤ | ៥៩១,៥ |
| | រោងចក្រអគ្គិសនី | គីឡូតោន | ៦,០ | ៤,៩ |
| ជីវឧស្ម័ន | លំនៅដ្ឋាន | ម៉ែត្រគូប | ២២,២ | ២២,៦ |
| ធ្យូង | លំនៅដ្ឋាន | គីឡូតោន | ៩១,០ | ៩៥,៦ |
| កាកអំពៅ | រោងចក្រអគ្គិសនី | គីឡូតោន | ៣៤,៨ | ២៦,០ |
| ធ្យូងអនាម័យ | លំនៅដ្ឋាន | គីឡូតោន | មិនមាន | មិនមាន |
| | ពាណិជ្ជកម្ម | គីឡូតោន | មិនមាន | មិនមាន |

## ២.៤. អគ្គិសនី

### ២.៤.១. ផលិតកម្មអគ្គិសនី

ប្រទេសកម្ពុជាផលិតថាមពលអគ្គិសនីដើរដោយប្រេងឥន្ធនៈ (ប្រេងម៉ាស៊ូត/ប្រេងខ្មៅ-HFO) ធ្យូងថ្ម (ប្រភេទអនុ-ប៊ីទុមីនឹស) ជីវម៉ាស (កាកអំពៅ អុស/កាកសំណល់) ថាមពលពន្លឺព្រះអាទិត្យ និងវារីអគ្គិសនី។ បច្ចុប្បន្ននេះវារីអគ្គិសនី និងរោងចក្រអគ្គិសនីដុតធ្យូងថ្ម គឺជាប្រភពថាមពលអគ្គិសនីដ៏សំខាន់។ ការផលិតថាមពលអគ្គិសនីសម្រាប់ឆ្នាំ២០២០-២០២១ ត្រូវបានផ្ដល់ទិន្នន័យដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា។ តារាង ២.៦ បង្ហាញពីផលិតកម្មអគ្គិសនីឆ្នាំ២០២០-២០២១។

តារាង២.៦ ផលិតកម្មអគ្គិសនី (លានគីឡូវ៉ាត់ម៉ោង)

| ឆ្នាំ | | ២០២០ | ២០២១ |
|---|---|---|---|
| ផលិតកម្មអគ្គិសនី | វារីអគ្គិសនី | ៣ ៩១៧,៦ | ៥ ១០៦,៦ |
| | ធ្យូងថ្ម | ៤ ២៧០,៨ | ៣ ៧៧៧,៤ |
| | ប្រេងឥន្ធនៈ | ៤៥៧,១ | ៥៦២,៤ |
| | កាកអំពៅ | ៥៥,៩ | ៤១,៨ |
| | អុស/កាកសំណល់ | ៩,៦ | ៧,៨ |
| | សូឡា | ២៩០,៣ | ៦១១,៣ |

## ២.៤.២. ការផ្គត់ផ្គង់អគ្គិសនី

ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងប្រទេសកម្ពុជាបានមកពីល្បាយប្រភពអគ្គិសនីដូចជាប្រភពក្នុងស្រុក (វារីអគ្គិសនី ធ្យូងថ្ម ប្រេង ថាមពលពន្លឺព្រះអាទិត្យ និងជីវម៉ាស) និងប្រភពអគ្គិសនីនាំចូលពីប្រទេសជិតខាង (ថៃ វៀតណាម និងឡាវ)។ ការនាំចូលអគ្គិសនីគឺដោយសារកត្តារដូវប្រាំងបរិមាណទឹកសម្រាប់ផលិតវារីអគ្គិសនីមានការថយចុះ។ ការកើនឡើងយ៉ាងខ្លាំងនៃតម្រូវការអគ្គិសនី ដោយសារកំណើនសេដ្ឋកិច្ចមានការកើនឡើង និងប្រភពអគ្គិសនីក្នុងស្រុកផ្គត់ផ្គង់មិនទាន់គ្រប់គ្រាន់ ទើបធ្វើឱ្យមានការនាំចូលថាមពល អគ្គិសនីពីប្រទេសជិតខាង។ ការវិនិយោគរោងចក្រអគ្គិសនីដុតធ្យូងថ្ម ថាមពលពន្លឺព្រះអាទិត្យ វារីអគ្គិសនី និងជីវម៉ាសក្នុងស្រុកបន្ថែម ដើម្បីកាត់បន្ថយការនាំចូលថាមពលអគ្គិសនីពីប្រទេសជិតខាង។ តារាង ២.៧ បង្ហាញពីការផ្គត់ផ្គង់អគ្គិសនីសរុបឆ្នាំ ២០២០-២០២១ ។

តារាង២.៧ ការផ្គត់ផ្គង់អគ្គិសនី (លានគីឡូវ៉ាត់ម៉ោង)

| ឆ្នាំ | ២០២០ | ២០២១ |
|---|---|---|
| ផលិតកម្មក្នុងស្រុក | ៩ ០០១,៣ | ១០ ១០៧,៣ |
| នាំចូល | ៣ ៨១៩,៧ | ៣ ៣៨៥,១ |
| សរុប | ១២ ៨២១,០ | ១៣ ៤៩២,៤ |

## ២.៤.៣. ការប្រើប្រាស់អគ្គិសនី

វិស័យប្រើប្រាស់ថាមពលអគ្គិសនីចុងក្រោយសំខាន់ៗមានចំនួនបីរួមមាន វិស័យឧស្សាហកម្ម វិស័យពាណិជ្ជកម្ម-សេវាកម្ម និងវិស័យលំនៅដ្ឋាន។ វិស័យពាណិជ្ជកម្មប្រើប្រាស់អគ្គិសនីជាចម្បង (អគារការិយាល័យ សណ្ឋាគារ ផ្សារទំនើប និងមន្ទីរពេទ្យ)។ បន្ទាប់មកគឺវិស័យលំនៅដ្ឋាន (ទីក្រុង និងជនបទ) និងវិស័យឧស្សាហកម្ម រួមទាំងតំបន់សេដ្ឋកិច្ចពិសេស។ យើងពុំទាន់មានការកត់ត្រាការប្រើប្រាស់អគ្គិសនីនៅស្ថានីយសាកអាគុយ កង់ ម៉ូតូ រថយន្តអគ្គិសនីសម្រាប់ការធ្វើដំណើរនៅឡើយទេ ដូច្នេះការសាកអាគុយត្រូវបានគិតបញ្ចូលក្នុងវិស័យលំនៅដ្ឋាន។ ដោយឡែកសម្រាប់វិស័យកសិកម្ម (ការបូមទឹក ការចិញ្ចឹមសត្វ) ពុំទាន់មានការកត់ត្រាការប្រើប្រាស់អគ្គិសនីនោះទេ។ ការប្រើប្រាស់អគ្គិសនីសម្រាប់ឆ្នាំ២០២០-២០២១ ត្រូវបានផ្តល់ទិន្នន័យដោយអាជ្ញាធរអគ្គិសនីកម្ពុជា។ តារាង២.៨ បង្ហាញពីការប្រើប្រាស់អគ្គិសនីសរុបឆ្នាំ២០២០-២០២១ ។

តារាង២.៨ ការប្រើប្រាស់អគ្គិសនី (លានគីឡូវ៉ាត់ម៉ោង)

| ឆ្នាំ | | ២០២០ | ២០២១ |
|---|---|---|---|
| ការប្រើប្រាស់អគ្គិសនី | លំនៅដ្ឋាន | ៣ ៨៨០,៩ | ៤ ២៣០,៣ |
| | ពាណិជ្ជកម្ម-សេវាកម្ម | ៣ ១៧០,៦ | ៣ ៣២៥,៤ |
| | ឧស្សាហកម្ម | ៤ ២៤៦,៦ | ៤ ២៦០,៨ |
| | កសិកម្ម | មិនមាន | មិនមាន |
| | ស្ថានីយសាកអាគុយ | មិនមាន | មិនមាន |

# ជំពូកទី៣៖ វិភាគការផ្គត់ផ្គង់ និងការប្រើប្រាស់ថាមពល

## ៣.១. ការផ្គត់ផ្គង់ថាមពលតាមប្រភេទឥន្ធនៈ

ការផ្គត់ផ្គង់ថាមពលសរុបនៅកម្ពុជាមានការកើនឡើងចន្លោះឆ្នាំ២០២០-២០២១ ពី ៧ ៥៧១ ktoe ដល់ ៧ ៥៧៣ ktoe ស្មើនឹង ០,០១% ក្នុងនោះ ប្រេងបានចូលរួមធំជាងគេ ៤២,៨៥% រួមចំណែកបន្ទាប់ដោយជីវម៉ាស ២៧,៧% ធ្យូងថ្ម ១៩,៦% វារីអគ្គិសនី ៥,១% ការនាំចូលអគ្គិសនីពីប្រទេសជិតខាង ៤,១% និងថាមពលដើរដោយថាមពលពន្លឺព្រះអាទិត្យ ០,៥%។ ការផ្គត់ផ្គង់ថាមពលពីប្រភពថាមពលដើរដោយថាមពលពន្លឺព្រះអាទិត្យ មានកំណើនខ្ពស់ជាងគេបំផុត ប្រមាណ ១១២% ដោយសារការបង្កើនអានុភាព ១០០ មេហ្គាវ៉ាត់ ចូលក្នុងបណ្ដាញជាតិ និងវារីអគ្គិសនីមានកំណើនខ្ពស់បន្ទាប់ ៣០,៣% ដោយសារភ្លៀងធ្លាក់ច្រើន នាំឱ្យវារីអគ្គិសនីដំណើរការបានល្អទាំងរដូវវស្សា និងរដូវប្រាំង និងបានកាត់បន្ថយការនាំចូលអគ្គិសនី ១១,៣%។ ចំណែក ជីវម៉ាស មានកំណើនត្រឹម ៣,៨% ដោយសារប្រជាពលរដ្ឋកាត់បន្ថយការប្រើប្រាស់អុសក្នុងការចម្អិនអាហារ រីឯប្រេងកើនឡើងត្រឹមតែ ០,២% ប៉ុណ្ណោះ (សារធាតុគីមីបន្ថែម MTBE សម្រាប់លាយជាមួយប្រេងសាំងកើនឡើង ២១៤,៣%) ដោយសារការដឹកជញ្ជូន និងការធ្វើដំណើរបានកាត់បន្ថយ ព្រោះប្រជាពលរដ្ឋមួយចំនួន ត្រូវបានរាំងខ្ទប់ក្នុងផ្ទះ ដើម្បីបង្ការជំងឺឆ្លងសកលកូវីដ-១៩ ។ ក្រាហ្វិក ៣.១ បង្ហាញពីការផ្គត់ផ្គង់ថាមពលសរុប ឆ្នាំ ២០២០-២០២១។




ក្រាហ្វិក ៣.១ ការផ្គត់ផ្គង់ថាមពលសរុប

## ៣.២. ល្បាយនៃការផ្គត់ផ្គង់ថាមពលសរុបតាមប្រភេទឥន្ធនៈ

### ៣.២.១. ល្បាយថាមពលផ្គត់ផ្គង់ក្នុងឆ្នាំ២០២០

នៅឆ្នាំ២០២០ ការផ្គត់ផ្គង់ថាមពលសរុបតាមប្រភេទឥន្ធនៈ ៧ ៥៧១ ktoe ក្នុងនោះ ប្រេងបានចូលរួមធំជាងគេ ៣ ២៣៧ ktoe ស្មើនឹង ៤២,៧៦% រួមចំណែកបន្ទាប់ដោយជីវម៉ាស/កាកសំណល់ មានចំនួន ២ ០៥៨ ktoe ស្មើនឹង ២៧,១៨% ខណៈធ្យូងថ្មមាន ១ ៥៧៩ ktoe ស្មើនឹង ២០,៨៦% វារីអគ្គិសនី ៣៣៧ ktoe ស្មើនឹង ៤,៤៥% ការនាំចូលអគ្គិសនីពីប្រទេសជិតខាង ៣២៨ ktoe ស្មើនឹង ៤,៣៣% និងថាមពលដើរដោយថាមពលពន្លឺព្រះអាទិត្យ ២៥ ktoe ស្មើនឹង ០,៣១%។




ក្រាហ្វិក ៣.២ ល្បាយនៃការផ្គត់ផ្គង់ថាមពលសរុបតាមប្រភេទឥន្ធនៈសម្រាប់ឆ្នាំ២០២០

### ៣.២.២. ល្បាយថាមពលផ្គត់ផ្គង់ក្នុងឆ្នាំ២០២១

នៅឆ្នាំ២០២១ ការផ្គត់ផ្គង់ថាមពលសរុបតាមប្រភេទឥន្ធនៈ ៧ ៥៧៣ ktoe ក្នុងនោះ ប្រេងបានចូលរួមធំជាងគេ ៣ ២៤៤ ktoe ស្មើនឹង ៤២,៨៤% រួមចំណែកដោយជីវម៉ាស/កាកសំណល់ ២ ១៣៧ ktoe ស្មើនឹង ២៨,២២% ធ្យូងថ្ម ១ ៣៨៧ ktoe ស្មើនឹង ១៨,៣២% វារីអគ្គិសនី ៤៣៩ ktoe ស្មើនឹង ៥,៨០% ការនាំចូលអគ្គិសនីពីប្រទេសជិតខាង ២៩១ ktoe ស្មើនឹង ៣,៨៤% និងថាមពលពន្លឺព្រះអាទិត្យ ៥៣ ktoe ស្មើនឹង ០,៧០% ។




ក្រាហ្វិក ៣.៣ ល្បាយនៃការផ្គត់ផ្គង់ថាមពលសរុបតាមប្រភេទឥន្ធនៈសម្រាប់ឆ្នាំ២០២១

## ៣.៣. ការប្រើប្រាស់ថាមពលសរុបតាមវិស័យ

ការប្រើប្រាស់ថាមពលសរុបមានការកើនឡើងនៅចន្លោះឆ្នាំ២០២០-២០២១ ពី ៦ ៣៩៨ ktoe ដល់ ៦ ៦៥៧ ktoe ដែលគិតជាកំណើនមធ្យមប្រចាំឆ្នាំ ប្រមាណ ៤,០% ក្នុងនោះ វិស័យដឹកជញ្ជូនបានប្រើប្រាស់ថាមពលច្រើនជាងគេ គឺរហូតដល់ ៣៦,៣៧%។ បន្ទាប់ពីនេះ វិស័យឧស្សាហកម្ម ៣៦,៣៧% លំនៅដ្ឋាន ១៦,៨៧% វិស័យសេវាកម្ម ៦,៤១% កសិកម្ម ២,២៤% នេសាទ ១,១% និងការប្រើប្រាស់មិនមែនថាមពល ២,២៩%។ ក្នុងអំឡុងនៃជំងឺឆ្លងសកលកូវីដ-១៩ វិស័យឧស្សាហកម្ម មានកំណើនការប្រើប្រាស់ថាមពលខ្ពស់ជាងគេ រហូតដល់ ៨,៩៨% ដោយសាររោងចក្រ-សហគ្រាស

មួយចំនួនធំ បានដំណើរការខ្សែសង្វាក់ផលិតកម្មជាធម្មតា ហើយវិស័យកសិកម្មកើនឡើង ៤,២% ដោយសារប្រជាកសិករនៅបន្តធ្វើស្រែចំការ។ វិស័យពាណិជ្ជកម្ម និងសេវាកម្ម មានការថយចុះ ២,១៣% ដោយសារអគាររដ្ឋាភិបាល សណ្ឋាគារ និងភោជនីយដ្ឋាន កាត់បន្ថយម៉ោងពេល ផ្អាកដំណើរការ ឬបញ្ឈប់ដំណើរការតែម្តង។ ដោយឡែក វិស័យដឹកជញ្ជូន កំណើនមានការថយចុះ មកត្រឹម ៣,៣៤% ប៉ុណ្ណោះ ដោយសារកាត់បន្ថយ និងផ្អាកសេវាកម្មដឹកជញ្ជូន។ ទន្ទឹមនឹងនេះផងដែរ ការប្រើប្រាស់ថាមពលសរុបសម្រាប់ការនេសាទថយចុះ ១៥,៣៨% ដោយសារអ្នកនេសាទភាគច្រើនពុំបានចេញទៅនេសាទ ឬផ្លាស់ប្តូរមុខរបរ។ ក្រាហ្វិក ៣.៤ បង្ហាញពីការប្រើប្រាស់ថាមពលសរុបតាមវិស័យឆ្នាំ២០២០-២០២១។



ក្រាហ្វិក ៣.៤ ការប្រើប្រាស់ថាមពលសរុបតាមវិស័យ

## ៣.៤. ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមវិស័យ

### ៣.៤.១. ល្បាយប្រើប្រាស់ថាមពលក្នុងឆ្នាំ២០២០

ការប្រើប្រាស់ថាមពលសរុបតាមវិស័យប្រចាំឆ្នាំ២០២០ មានចំនួន ៦ ៣៩៨ ktoe ក្នុងនោះវិស័យដឹកជញ្ជូនបានប្រើប្រាស់ថាមពលធំជាងគេ ចំនួន ២ ៣០៥ ktoe ស្មើនឹង ៣៦,០៣% រួមបញ្ចូលដោយ ចំនួន ២ ២៧២ ktoe ស្មើនឹង ៣៥,៥១% វិស័យឧស្សាហកម្ម។ ដោយឡែក វិស័យលំនៅដ្ឋានមានចំនួន ១ ០៤៦ ktoe ស្មើនឹង ១៦,៣៥% ពាណិជ្ជកម្ម និងសេវាកម្មចំនួន ៤២៣ ktoe ស្មើនឹង ៦,៦១% កសិកម្មចំនួន ១៤៣ ktoe ស្មើនឹង ២,២៤% នេសាទចំនួន ៧៨ ktoe ស្មើនឹង ១,២២% និងការប្រើប្រាស់មិនមែនថាមពល ចំនួន ១៣១ ktoe ស្មើនឹង ២,០៥% ។




ក្រាហ្វិក ៣.៥ ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមវិស័យឆ្នាំ២០២០

## ៣.៤.២. ល្បាយប្រើប្រាស់ថាមពលក្នុងឆ្នាំ២០២១

ការប្រើប្រាស់ថាមពលសរុបតាមវិស័យប្រចាំឆ្នាំ២០២១ មានចំនួន ៦ ៦៥៦ ktoe ក្នុងនោះវិស័យឧស្សាហកម្មបានប្រើប្រាស់ថាមពលធំជាងគេ ចំនួន ២ ៤៧៦ ktoe ស្មើនឹង ៣៧,១៩% រួមបញ្ចូលដោយ ចំនួន ២ ២២៨ ktoe ស្មើនឹង ៣៣,៤៧% ពីវិស័យដឹកជញ្ជូន ខណៈវិស័យលំនៅដ្ឋានមានចំនួន ១ ១៥៦ ktoe ស្មើនឹង ១៧,៣៧% ពាណិជ្ជកម្ម និង សេវាកម្មចំនួន ៤១៤ ktoe ស្មើនឹង ៦,២២% កសិកម្មចំនួន ៤១៤ ktoe ស្មើនឹង ២,២៤% នេសាទចំនួន ៦៦ ktoe ស្មើនឹង ០,៩៩% និងការប្រើប្រាស់មិនមែនថាមពលចំនួន ១៦៨ ktoe ស្មើនឹង ២,៥២%។




ក្រាហ្វិក ៣.៦ ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមវិស័យឆ្នាំ២០២១

## ៣.៥. ការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ធនៈ

នៅឆ្នាំ២០២០-២០២១ យើងឃើញថា ការប្រើប្រាស់ថាមពលសរុប បានកើនឡើង ពី ៦ ៣៩៧ ktoe ដល់ ៦ ៦៥៧ ktoe ដែលគិតជាកំណើនមធ្យមប្រចាំឆ្នាំ ៤,១% ក្នុងនោះ

ថាមពលប្រេង ត្រូវបានប្រើប្រាស់ច្រើនជាងគេ ៤៨,៣៦% បន្ទាប់មក ថាមពលជីវម៉ាស ២៩,៦៤% ថាមពលអគ្គិសនី ១៥,២២% ។ ធ្យូងថ្មដែលប្រើប្រាស់ក្នុងរោងចក្រស៊ីម៉ង់ត៍ មានកំណើនប្រើប្រាស់ខ្ពស់ជាងគេ គឺប្រមាណ ២៦,៣៤% និងថាមពលអគ្គិសនី ៤,៦៣% ដោយសារតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋមានការកើនឡើង ជាពិសេសក្នុងវិស័យអចលនទ្រព្យ។ ដោយឡែក ការប្រើប្រាស់ថាមពលជីវម៉ាស បានកើនឡើង ៣,៩៥% និងថាមពលប្រេង ១,១៨% ដោយសារផលប៉ះពាល់នៃជំងឺឆ្លងសកលកូវីដ-១៩។ ក្រាហ្វិក ៣.៧ បង្ហាញពីការប្រើប្រាស់ថាមពលសរុបឆ្នាំ២០២០-២០២១។




ក្រាហ្វិក ៣.៧ ការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ទនៈ

## ៣.៦. ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ធនៈ

### ៣.៦.១. សម្រាប់ឆ្នាំ២០២០

ការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ធនៈប្រចាំឆ្នាំ២០២០ មានចំនួន ៦ ៣៩៧ ktoe ក្នុងនោះប្រើប្រាស់ប្រេងឥន្ធនៈធំជាងគេចំនួន ៣ ១៣៨ ktoe ស្មើនឹង ៤៩,០៥% ជីវម៉ាសចំនួន ១ ៨៩៧ ktoe ស្មើនឹង ២៩,៦៥% អគ្គិសនីចំនួន ៩៧១ ktoe ស្មើនឹង ១៥,១៨% ធ្យូងថ្មចំនួន ៣៩១ ktoe ស្មើនឹង ៦,១១% ។




ក្រាហ្វិក ៣.៨ ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ធនៈឆ្នាំ២០២០

### ៣.៦.២. សម្រាប់ឆ្នាំ២០២១

ការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ធនៈប្រចាំឆ្នាំ២០២១ មានចំនួន ៦ ៦៥៧ ktoe ក្នុងនោះប្រើប្រាស់ប្រេងឥន្ធនៈធំជាងគេចំនួន ៣ ១៧៥ ktoe ស្មើនឹង ៤៧,៦៩% ជីវម៉ាសចំនួន ១ ៩៧២ ktoe ស្មើនឹង ២៩,៦២% អគ្គិសនីចំនួន ១ ០១៦ ktoe ស្មើនឹង ១៥,២៦% ធ្យូងថ្មចំនួន ៤៩៤ ktoe ស្មើនឹង ៧,៤២% ។




ក្រាហ្វិក ៣.៩ ល្បាយនៃការប្រើប្រាស់ថាមពលសរុបតាមប្រភេទឥន្ធនៈឆ្នាំ២០២១

## ៣.៧. ការប្រើប្រាស់ធ្យូងថ្ម

កម្ពុជាពឹងផ្អែកលើការនាំចូលធ្យូងថ្មពីក្រៅប្រទេសទាំងស្រុង សម្រាប់ផលិតថាមពលអគ្គិសនី និងប្រើប្រាស់ក្នុងឧស្សាហកម្មផលិតស៊ីម៉ង់ត៍។ ការនាំចូលធ្យូងថ្មមានការថយចុះនៅឆ្នាំ២០២០-២០២១ ពី ១ ៦២៦ ktoe មកត្រឹម ១ ៤៣៧ ktoe ប្រមាណជា ១៦,២% ក្នុងនោះ ៧៣,៨៥%នៃធ្យូងថ្មត្រូវបានប្រើប្រាស់សម្រាប់ផលិតថាមពលអគ្គិសនី និង៣១,៤១% ទៀតសម្រាប់ឧស្សាហកម្ម។ ក្រាហ្វិក ៣.១០ បង្ហាញពីការប្រើប្រាស់ធ្យូងថ្មក្នុងឆ្នាំ២០២០-២០២១។




ក្រាហ្វិក ៣.១០ ការប្រើប្រាស់ធ្យូងថ្មក្នុងឆ្នាំ២០២០-២០២១

## ៣.៨. ការប្រើប្រាស់ប្រេងឥន្ធនៈ

ជាក់ស្តែង កម្ពុជាក៏ជាប្រទេសមួយដែលមានធនធានប្រេងដ៏គួរឱ្យកត់សម្គាល់នៅក្នុងតំបន់អាស៊ាន ប៉ុន្តែដោយសារកង្វះការវិនិយោគ ទើបកម្ពុជាត្រូវនាំចូលប្រេងឥន្ធនៈ ១០០% ពីក្រៅប្រទេសសម្រាប់យកមកធ្វើការផ្គត់ផ្គង់ និងប្រើប្រាស់តាមតម្រូវការ។ នៅឆ្នាំ២០២០-២០២១ ការនាំចូលប្រេងឥន្ធនៈ បានកើនឡើងពី ៧ ៧១២ ktoe ដល់ ៧ ៧១៤ ktoe ដែលគិតជាកំណើនមធ្យមប្រចាំឆ្នាំ ០,០៣% ក្នុងនោះ ត្រូវបានប្រើប្រាស់ច្រើនជាងគេនៅក្នុងវិស័យឧស្សាហកម្មចំនួន ៤ ៧៤៨ ktoe ស្មើនឹង ៣០,៧៨% បន្ទាប់មកវិស័យដឹកជញ្ជូនចំនួន ៤ ៥៣៣ ktoe ស្មើនឹង ២៩,៣៩% វិស័យលំនៅដ្ឋាន ពាណិជ្ជកម្ម សេវាកម្ម និងកសិកម្មចំនួន ៣ ៤៧៥ ktoe ស្មើនឹង ២២,៥៣% ប្រើប្រាស់ផលិតអគ្គិសនីចំនួន ២ ៣៧១ ktoe ស្មើនឹង ១៥,៣៧% និងការប្រើប្រាស់មិនមែនថាមពលចំនួន ២៩៩ ktoe ស្មើនឹង ១,៩៤% ។ ក្រាហ្វិក ៣.១១ បង្ហាញពីការប្រើប្រាស់ប្រេងឥន្ធនៈឆ្នាំ ២០២០-២០២១។




ក្រាហ្វិក ៣.១១ ការប្រើប្រាស់ប្រេងឥន្ធនៈ

## ៣.៩. ការប្រើប្រាស់ជីវម៉ាស

អុស និងធ្យូង គឺជាមធ្យោបាយចម្អិនម្ហូបអាហារដ៏ចម្បងរបស់ប្រជាពលរដ្ឋខ្មែរ តាំងពីយូរលង់មកហើយ។ ប៉ុន្តែក្រោយមកតាមរយៈនវានុវត្តន៍ និងបរិវត្តន៍បច្ចេកវិទ្យា នាំឱ្យយើងទាំងអស់គ្នា មានសម្ភារ ឧបករណ៍ទំនើប និងថ្មីៗ សម្រាប់ចម្អិនម្ហូបអាហារតាមច្រើនជម្រើស ដូចជា ចង្ក្រានអគ្គិសនី ឬ ចង្ក្រានជីវឧស្ម័ន ជាដើម។

បើទោះបច្ចុប្បន្ននេះ ប្រជាពលរដ្ឋយើងភាគច្រើន បានផ្លាស់ប្តូរឥរិយាបថ មកប្រើប្រាស់សម្ភារអគ្គិសនី ដើម្បីចម្អិនម្ហូបអាហារ ជាពិសេស ប្រជាពលរដ្ឋនៅទីក្រុង និងតំបន់ទីប្រជុំជន តែយ៉ាងណាការប្រើប្រាស់អុស និងធ្យូង ក៏នៅតែជាតម្រូវការមួយផ្នែកសម្រាប់ប្រជាពលរដ្ឋនៅតំបន់ជនបទ (តំបន់ដាច់ស្រយាល និងតំបន់ភ្នំ)។ លើសពីនោះ សមាសធាតុជីវម៉ាសផ្សេងៗ ដូចយ៉ាង កាកអំពៅ អង្កាម និងសំណល់កសិកម្ម ក៏បានចូលរួមយ៉ាងសំខាន់ផងដែរ ក្នុងដំណើរការផលិតថាមពលអគ្គិសនី។

នៅឆ្នាំ២០២០-២០២១ ការប្រើប្រាស់ជីវម៉ាស បានកើនឡើងពី ២ ០៦៨ ktoe ដល់ ២ ១១៧៩ ktoe ដែលគិតជាកំណើនមធ្យមប្រចាំឆ្នាំ ៥,៣៧% ក្នុងនោះ វិស័យឧស្សាហកម្ម និងសិប្បកម្មបានប្រើប្រាស់ច្រើនជាងគេចំនួន ២ ៧០២ ktoe ស្មើនឹង ៦៣,៦៤% ភាគច្រើនប្រើប្រាស់សម្រាប់ផលិតកម្មឥដ្ឋ (ឡឥដ្ឋ) បន្ទាប់មកលំនៅដ្ឋានចំនួន ១ ១៦៧ ktoe ស្មើនឹង ២៧,៤៨% សម្រាប់ចម្អិនម្ហូបអាហារ ផលិតធ្យូងចំនួន ២៩៩ ktoe ស្មើនឹង ៧,០៤% និងផលិតអគ្គិសនីចំនួន ៧៨ ktoe ស្មើនឹង ១,៨៤% ។ ក្រាហ្វិក ៣.១២ បង្ហាញពីការប្រើប្រាស់ជីវម៉ាសឆ្នាំ២០២០-២០២១។




ក្រាហ្វិក ៣.១២ ការប្រើប្រាស់ជីវម៉ាស

## ជំពូកទី ៤៖ ការផលិត និងការប្រើប្រាស់អគ្គិសនី

ការអភិវឌ្ឍប្រភពអគ្គិសនីនៅកម្ពុជា មានកំណើនខ្ពស់គួរឱ្យកត់សម្គាល់។ នៅឆ្នាំ ២០២០-២០២១ ចំនួន ១ ០៦៦ ktoe ដល់ ១ ១២៦ ktoe គិតជាកំណើនមធ្យមប្រចាំឆ្នាំ ១៤,៥៣% ក្នុងនោះ វារីអគ្គិសនី បានចូលរួមផលិតអគ្គិសនីច្រើនជាងគេ ៧៦៦ ktoe ស្មើនឹង ៣៤,៩៥% បន្ទាប់មក ធ្យូងថ្ម ៦៣៤ ktoe ស្មើនឹង ២៨,៩២% ជីវម៉ាសចំនួន ១០ ktoe ស្មើនឹង ០,៤៦% និងសូឡា ៧៧ ktoe ស្មើនឹង ៣,៥១% ប្រេង ៨៦ ktoe ស្មើនឹង ៣,៩២% និងការនាំចូលពីប្រទេសជិតខាង (ថៃ វៀតណាម និងឡាវ) ចំនួន ៦១៩ ktoe ស្មើនឹង ២៨,២៤%។ បើយើងគិតតែលើការផលិតអគ្គិសនីក្នុងស្រុក ឃើញថា វារីអគ្គិសនី នៅតែជាអ្នកចូលរួមផលិតអគ្គិសនីខ្ពស់ជាងគេដដែល ប្រមាណ ៤៩% បន្ទាប់មក ថាមពលធ្យូងថ្មមានទំហំ ៤០% ដែលនាំឱ្យកម្ពុជា មានការផលិតអគ្គិសនីពីថាមពលកកើតឡើងវិញសរុប ៥៤% ដោយមានការចូលរួមពីថាមពលពន្លឺព្រះអាទិត្យ ៥% និង ជីវម៉ាស ១%។ ក្រាហ្វិក ៤.១ បង្ហាញពីការផលិតអគ្គិសនីសរុបតាមប្រភេទឥន្ធនៈឆ្នាំ២០២០-២០២១។




ក្រាហ្វិក ៤.១ ការផលិតអគ្គិសនីសរុបតាមប្រភេទឥន្ធនៈ

## ៤.១. ការប្រើប្រាស់អគ្គិសនីតាមវិស័យ

ការប្រើប្រាស់អគ្គិសនីសរុបនៅឆ្នាំ២០២០-២០២១ បានកើនឡើងពី ៩៧២ ktoe ដល់ ៩៩៣ ktoe គិតជាកំណើនមធ្យមប្រចាំឆ្នាំ ១៤,៥% ក្នុងនោះវិស័យឧស្សាហកម្ម បានប្រើប្រាស់អគ្គិសនីច្រើនជាងគេចំនួន ៧៣២ ktoe ស្មើនឹង ៣៧,៣% ដោយសារតែ រោងចក្រ-សហគ្រាសមួយចំនួនធំ បានដំណើរការខ្សែសង្វាក់ផលិតកម្មជាធម្មតា វិស័យ ពាណិជ្ជកម្ម និងសេវាកម្ម ចំនួន ៥៥៩ ktoe ស្មើនឹង ២៨,៤%  លំនៅដ្ឋាន ៦៦៨ ktoe ស្មើនឹង ៣៤% ដោយសារការរាំងខ្ទប់ប្រជាពលរដ្ឋនៅក្នុងផ្ទះ។ ក្រាហ្វិក ៤.២ បង្ហាញពីការ ប្រើប្រាស់អគ្គិសនីតាមវិស័យឆ្នាំ២០២០-២០២១។




ក្រាហ្វិក ៤.២ ការប្រើប្រាស់អគ្គិសនីតាមវិស័យ

# ជំពូកទី ៥៖ តារាងតុល្យភាពថាមពល

## ៥.១. ការរៀបចំតារាងតុល្យភាពថាមពល

ស្ថិតិថាមពលដែលមានទំហំខ្នាតខុស និងផ្សេងគ្នា ដើរតួនាទីសំខាន់ណាស់ក្នុងការបំពេញទិន្នន័យ និងផ្តល់ភាពងាយស្រួលក្នុងការប្រមូលទិន្នន័យសម្រាប់ការរៀបចំតារាងតុល្យភាពថាមពលរវាងការផ្គត់ផ្គង់ និងការប្រើប្រាស់ថាមពលគ្រប់ប្រភេទ។ សារប្រយោជន៍មួយទៀតនៃស្ថិតិថាមពល គឺការផ្តល់ទិន្នន័យអំពីលំហូរនៃការផ្គត់ផ្គង់ និងតម្រូវការថាមពលគ្រប់ប្រភេទ រួមមានផលិតកម្ម ការនាំចូល ការនាំចេញ ការបំប្លែង និងការប្រើប្រាស់របស់ប្រទេសនីមួយៗ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការប៉ាន់ស្មាននៃការផ្គត់ផ្គង់ថាមពល ការព្យាករណ៍សេចក្តីត្រូវការថាមពល និងការសិក្សាអំពីការអភិវឌ្ឍ និងជម្រើសថាមពល ដើម្បីឈានទៅការរៀបចំផែនការអភិវឌ្ឍថាមពលប្រកបដោយចីរភាព។

តារាងតុល្យភាពថាមពល គឺជាចំណុចចាប់ផ្តើមដ៏ល្អមួយសម្រាប់ការបង្កើតនូវសូចនាករផ្សេងៗ នៃការប្រើប្រាស់ និងប្រសិទ្ធភាពថាមពល (ឧទាហរណ៍៖ ការប្រើប្រាស់ថាមពលធៀបជាមួយប្រជាជនម្នាក់ ឬ ធៀបជាមួយផលិតផលក្នុងស្រុកសរុប (GDP)។

## ៥.២. គោលការណ៍គ្រឹះនៃតារាងតុល្យភាពថាមពល

តារាងតុល្យភាពថាមពល គឺជាក្របខ័ណ្ឌគណនេយ្យភាពមួយសម្រាប់ការរៀបចំចងក្រង និងប្រមូលផ្តុំទិន្នន័យផ្នែកផ្គត់ផ្គង់ និងប្រើប្រាស់ថាមពលគ្រប់ប្រភេទរបស់ប្រទេសជាតិនីមួយៗក្នុងរយៈពេលកំណត់មួយឆ្នាំ ហើយតារាងនេះរៀបចំបំពេញគ្រប់ទម្រង់ថាមពលដែលមានឯកតាធៀបរួមមួយ និងបង្ហាញទំនាក់ទំនងរវាងធាតុចូល និងធាតុចេញតាមរយៈនីតិវិធីការបំប្លែងថាមពល។

តារាងតុល្យភាពថាមពល គឺជាម៉ាទ្រីសមួយដែលបង្ហាញទំនាក់ទំនងរវាងផលិតផលថាមពល (ផ្នែកទទឹងតារាង) និងលំហូរថាមពល (ផ្នែកបណ្តោយតារាង)។ ចំពោះផ្នែកទទឹងតារាង គឺជាក្រុមផលិតផលថាមពលក្នុងទម្រង់ដើម ឬទម្រង់កែច្នៃ ហើយក្រឡា

តារាងនីមួយៗនៅផ្នែកទទឹងតារាងនេះ បង្ហាញពីលំហូរថាមពលដែលត្រូវជាមួយក្រុមផលិតផល ថាមពល ដូចបានកំណត់តាមឈ្មោះនៅផ្នែកបណ្ដោយតារាង។

គោលបំណងសំខាន់របស់តារាងតុល្យភាពថាមពល ឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងផលិតកម្មថាមពលបឋម (លំហូរថាមពលផ្សេងទៀត ដូចជាការនាំចូល ឬ ការនាំចេញ) ការបំប្លែងថាមពល និងការប្រើប្រាស់ថាមពល។ ដូចនេះ តារាងតុល្យភាពថាមពលត្រូវបានបែងចែកជាបីប្លុកសំខាន់ៗ ដែលបានបង្ហាញក្នុងរូបភាព ៥.១ ដូចខាងក្រោម៖




រូបភាព ៥.១ លំហូរថាមពលក្នុងតារាងតុល្យភាពថាមពល

- <u>ការផ្គត់ផ្គង់ថាមពលបឋម</u>៖ សំដៅលើការបង្ហាញលំហូរការនាំចូល និងការនាំចេញថាមពលក្នុងប្រទេសមួយ ក៏ដូចជាបង្ហាញពីការផ្លាស់ប្តូរស្តុក ដើម្បីផ្តល់ព័ត៌មានបរិមាណថាមពលរបស់ប្រទេសមួយក្នុងរយៈពេលកំណត់មួយ។ លំហូរនៃការផ្គត់ផ្គង់ថាមពលរួមបញ្ចូលផ្នែកផលិតកម្មទំនិញថាមពលបឋម និងការនាំចូលនៃទំនិញថាមពលបឋម និងបន្ទាប់បន្សំ។ ដូចនេះ បរិមាណសរុបនៃតុល្យភាពសម្រាប់ការផ្គត់ផ្គង់ថាមពល ត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

***ការផ្គត់ផ្គង់ថាមពលបឋមសរុប = ផលិតកម្មដើម (ជួរដេកទី១) + ការនាំចូល (ជួរដេកទី២) + ការនាំចេញ + ឥន្ធនៈសម្រាប់នាវាចរណ៍អន្តរជាតិ + ឥន្ធនៈសម្រាប់អាកាសយានអន្តរជាតិ + ការផ្លាស់ប្តូរស្តុក (ជួរដេកទី៦)***។

- <u>ការបំប្លែង និងបញ្ជូនថាមពល</u>៖ សំដៅលើការបង្ហាញលំហូរថាមពលដែលត្រូវបំប្លែងបញ្ជូន និងប្រើប្រាស់យ៉ាងដូចម្តេចនៅក្នុងផ្នែកឧស្សាហកម្មថាមពលសម្រាប់ការប្រើប្រាស់ខ្លួនឯង និង កំហាតបង់ នៅពេលបញ្ជូន និងចែកចាយ។ ផលិតកម្មអគ្គិសនី និងដំណើរការចម្រាញ់ប្រេងកាត គឺជាសកម្មភាពដ៏សំខាន់មួយក្នុងផ្នែកនេះ។
- <u>ការប្រើប្រាស់ថាមពលសរុប</u>៖ សំដៅលើការបង្ហាញលំហូរថាមពលដែលត្រូវប្រើប្រាស់តាមផ្នែកនីមួយៗ។ លំហូរនេះ ឆ្លុះបញ្ចាំងពីការប្រើប្រាស់ថាមពលសរុប និងការប្រើប្រាស់មិនមែនជាថាមពលនៃផលិតផលថាមពល។ ដូចនេះ ផ្នែកនៃការប្រើប្រាស់ថាមពលសរុបនេះ មិនបានរាប់បញ្ចូលការបែងចែកប្រេង និងការផលិតថាមពលផ្សេងៗទៀតសម្រាប់ប្រើប្រាស់ក្នុងដំណើរការបំប្លែង និងសម្រាប់បម្រើតម្រូវការថាមពលក្នុងឧស្សាហកម្មថាមពលទេ។ ការប្រើប្រាស់ថាមពលសរុប ចែកចេញជាបីប្រភេទសំខាន់ៗ គឺ ១-សកម្មភាពផលិតកម្ម

ការសាងសង់ និងឧស្សាហកម្មរ៉ែមិនមែនឥន្ធនៈ ២-ការដឹកជញ្ជូន និង ៣-ផ្សេងៗ (ផ្នែកកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ផ្នែកពាណិជ្ជកម្ម និង សេវាសាធារណៈ ផ្នែកលំនៅដ្ឋាន និងផ្នែកអ្នកប្រើប្រាស់ផ្សេងៗទៀត)។

កម្រិតល្អៀងស្ថិតិ គឺជាភាពខុសគ្នារវាងការផ្គត់ផ្គង់សរុប និងការប្រើប្រាស់ថាមពលសរុបនៃផលិតផលថាមពល។ កម្រិតល្អៀងនេះ កើតឡើងដោយសារភាពខុសគ្នានៃការកំណត់បញ្ហា និងភាពជាក់ស្តែងផ្សេងគ្នា ក្នុងពេលប្រមូលទិន្នន័យពីផ្នែកផ្គត់ផ្គង់ និងតម្រូវការ។ បញ្ហាដែលនាំឱ្យមានភាពល្អៀងស្ថិតិនេះ ច្រើនតែកើតឡើងពីការជ្រើសរើសសំណាក ប្រភពទិន្នន័យខុសគ្នា រយៈពេលខុសគ្នា លក្ខណៈបច្ចេកទេសឥន្ធនៈខុសគ្នា មេគុណបំប្លែងខុសគ្នាពីមាឌទៅម៉ាស ឬការបំប្លែងពីម៉ាសទៅថាមពលក្នុងផ្នែកផ្គត់ផ្គង់និងផ្នែកប្រើប្រាស់ក្នុងទម្រង់តារាងតុល្យភាពខុសគ្នា។ ដើម្បីរកកម្រិតល្អៀងស្ថិតិ យើងត្រូវធ្វើការគណនា ដោយធ្វើផលដកផ្នែកផ្គត់ផ្គង់សុទ្ធ និងផ្នែកប្រើប្រាស់ ដូចបង្ហាញក្នុងរូបមន្តខាងក្រោម៖

***កម្រិតល្អៀងស្ថិតិ = ផ្នែកផ្គត់ផ្គង់ថាមពលដើមសរុប + ការបញ្ជូន + ការបំប្លែង + ការប្រើប្រាស់ខ្លួនឯង ឧស្សាហកម្មថាមពល + កំហាតបង់ - ការប្រើប្រាស់សរុប***

## ៥.៣. វិធីសាស្ត្រគណនា

វិធីសាស្ត្រគណនាសម្រាប់បង្កើតតុល្យភាពថាមពល ការកំណត់អត្ថន័យ និងការរៀបចំជាក្រុមផលិតផលថាមពល ព្រមទាំងនិយមន័យបច្ចេកទេសស្ថិតិ គឺជាសុខដុមភាវូបនីយកម្មជាមួយស្តង់ដាអន្តរជាតិដែលមានស្រាប់។ ទិន្នន័យតុល្យភាពថាមពល ធ្វើឡើងដោយផ្អែកតាមទិន្នន័យនីមួយៗដែលប្រមូល និងចងក្រងចេញពី

កម្រងសំណួរធ្យូងថ្ម ប្រេង ឧស្ម័ន អគ្គិសនី និងថាមពលកកើតឡើងវិញ ដែលទិន្នន័យនេះ ជាទូទៅ មានខ្នាតគិតតាមរង្វាស់ទំហំឯកតានៃប្រភេទនីមួយៗ។ ដូច្នេះទិន្នន័យនៃប្រភេទនីមួយៗដែលមានឯកតាខុសគ្នា ត្រូវបំប្លែងឱ្យទៅជាខ្នាតរួមមួយ ដែលហៅថា "តោនសមមូលប្រេង" ( Ton of Oil Equivalent ) ។

## ៥.៣.១. កម្រងសំណួរថាមពល

ទិន្នន័យថាមពលបឋម ដែលតម្រូវឱ្យការរៀបចំតារាងតុល្យភាពថាមពលឆ្នាំ ២០២០-២០២១ បានពីក្រុមការងារបច្ចេកទេសអន្តរស្ថាប័នរួចហើយ ដែលទិន្នន័យទាំងនោះត្រូវបានបញ្ចូលទៅក្នុងកម្រងសំណួរនីមួយៗ រួមមានកម្រងសំណួរធ្យូងថ្ម ប្រេង អគ្គិសនី និងថាមពលកកើតឡើងវិញ ។ កម្រងសំណួរទាំងនេះ ត្រូវបានកែសម្រួលទៅតាមស្ថានភាពថាមពលជាក់ស្តែងក្នុងព្រះរាជាណាចក្រកម្ពុជា ដោយដកស្រង់ចេញពីវេទិកាសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក និងសមាគមអាស៊ាន ដើម្បីប្រមូលផ្តុំស្ថិតិថាមពលសំខាន់ៗ និងជួយផ្តល់ការត្រួតពិនិត្យទិន្នន័យឱ្យបានពេញលេញ ព្រោះកម្រងសំណួរទាំងនេះនឹងជួយឱ្យមានតុល្យភាពរវាងការផ្គត់ផ្គង់និងការប្រើប្រាស់ប្រភេទថាមពលនីមួយៗ។ បន្ទាប់ពីបំពេញទិន្នន័យក្នុងកម្រងសំណួររួចហើយ ទិន្នន័យទាំងនេះនឹងប្រើប្រាស់សម្រាប់បង្កើតតារាងតុល្យភាពថាមពល តាមរយៈកម្មវិធីកុំព្យូទ័រ IEA.EB. Builder ។

## ៥.៣.២. ខ្នាត និងការបំប្លែង

គ្រប់ការបញ្ចូលទិន្នន័យក្នុងតារាងតុល្យភាពថាមពល មានខ្នាតថាមពលរួមមួយនោះគឺ គីឡូកាឡូរី ឬ ជីហ្គាស៊ូល ឬគីឡូតោនសមមូលប្រេង ឬ តោនសមមូលប្រេង។ តារាងតុល្យភាពថាមពលនៅកម្ពុជា ឆ្នាំ២០២០-២០២១ បានជ្រើសរើស និងប្រើប្រាស់

ខ្នាតតោនសមមូលប្រេង ដែល ១ តោនសមមូលប្រេង ស្មើនឹង ១០,៧ ជីកាឡូរី (៤១,៨៦៨ ជីហ្គាស្សូល) ហើយមានតម្លៃកម្តៅចំនួនពីរ គឺ តម្លៃកាឡូរីសុទ្ធ និងតម្លៃកាឡូរីសរុប ដែលភាពខុសគ្នារវាងតម្លៃទាំងពីរនេះគឺ៖

- ធ្យូងថ្ម និងប្រេង៖ តម្លៃកាឡូរីសុទ្ធតិចជាងប្រហែល ៥ ភាគរយនៃតម្លៃកាឡូរីសរុប
- ឧស្ម័ន៖ តម្លៃកាឡូរីសុទ្ធតិចជាងប្រហែល ១០ ភាគរយនៃតម្លៃកាឡូរីសរុប

ម៉្យាងវិញទៀត ទិន្នផលអគ្គិសនីធៀបនឹងថាមពលកម្តៅបឋមត្រូវបានសន្មត់ដូចខាងក្រោម៖

- វារីអគ្គិសនី៖ ១០០ ភាគរយ
- ប្រេងខ្មៅ និងម៉ាស៊ូត៖ ២៨ - ៣៥ ភាគរយ
- នុយក្លេអ៊ែរ៖ ៣៣ ភាគរយ
- កម្តៅផែនដី៖ ១០ ភាគរយ
- ពន្លឺព្រះអាទិត្យ ខ្យល់ ជំនោរលំនាច និងរលកសមុទ្រ៖ ១០០ ភាគរយ

ចំណែកមេគុណបំប្លែងដែលប្រើប្រាស់សម្រាប់ឯកតាខុសៗគ្នានៅកម្ពុជាសម្រាប់ផលិតប្រេង ថាមពល អគ្គិសនី ធ្យូងថ្ម អុស ធ្យូង បានបង្ហាញក្នុងតារាង ៥.១។

តារាង ៥.១ មេគុណបំប្លែងផលិតផលថាមពលនៅកម្ពុជា

| ផលិតផលថាមពល | ឯកតាដើម | តោនសមមូលប្រេង |
| --- | --- | --- |
| ធ្យូងថ្មអនុ-ប៊ីទុមីនឹស | ម៉ែតទ្រិសតោន | ០,៤៥១៤ |
| ធ្យូងថ្មប៊ីទុមីនឹស | ម៉ែតទ្រិសតោន | ០,៦១៦២ |
| ធ្យូងថ្មលីណាយច៍ | ម៉ែតទ្រិសតោន | ០,២៨៤២ |
| សារធាតុគីមីបន្ថែម | ម៉ែតទ្រិសតោន | ០,៦០០០ |
| ឧស្ម័នណាប់តា | ម៉ែតទ្រិសតោន | ១,០៧៤៨ |
| ឧស្ម័ន LPG | ម៉ែតទ្រិសតោន | ១,១២៩៧ |
| ប្រេងសាំង | ម៉ែតទ្រិសតោន | ១,០៧០០ |
| ប្រេងយន្តហោះ | ម៉ែតទ្រិសតោន | ១,០៦៥៣ |
| ប្រេងកាត | ម៉ែតទ្រិសតោន | ១,០៤៦១ |
| ប្រេងម៉ាស៊ូត | ម៉ែតទ្រិសតោន | ១,០៣៤២ |
| ប្រេងខ្មៅ | ម៉ែតទ្រិសតោន | ០,៩៣១៥ |
| ប្រេងខ្មៅស្អិត | ម៉ែតទ្រិសតោន | ០,៩៣១៥ |
| ប្រេងរំអិល | ម៉ែតទ្រិសតោន | ១,០០៣២ |
| ថាមពលអគ្គិសនី | មេហ្គាវ៉ាត់ម៉ោង | ០,០៨៦០ |
| អុស និងកម្ទេចឈើ | ម៉ែតទ្រិសតោន | ០,៣៨១៩ |
| ធ្យូងចម្អិន | ម៉ែតទ្រិសតោន | ០,៦៨៧៩ |
| ជីវឧស្ម័ន | ម៉ែតទ្រិសតោន | ០,៥២៥៥ |
| កាកអំពៅ | ម៉ែតទ្រិសតោន | ០,១៨០០ |

**ប្រភព៖** IEB Balance Builder

# ជំពូកទី ៦៖ សេចក្តីសន្និដ្ឋាន និងទិសដៅបន្ត

## ៦.១. សេចក្តីសន្និដ្ឋាន

ការរៀបចំសៀវភៅរបាយការណ៍ "ស្ថិតិនិងតារាងតុល្យការថាមពលជាតិឆ្នាំ ២០២០-២០២១" អាចឱ្យរាជរដ្ឋាភិបាលកម្ពុជា សម្រេចចក្ខុវិស័យក្នុងការផ្គត់ផ្គង់ថាមពលបានគ្រប់គ្រាន់ អាចទុកចិត្តបាន តាមវិស័យនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយយកចិត្តទុកដាក់ពង្រឹងសន្តិសុខនៃការផ្គត់ផ្គង់និងការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព ផ្តល់អាទិភាពជាអតិបរមាដល់ការផ្គត់ផ្គង់និងការប្រើប្រាស់ថាមពលក្នុងស្រុក ដើម្បីចូលរួមកាត់បន្ថយការផ្គត់ផ្គង់និងការប្រើប្រាស់ថាមពលដែលមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គម។ ការធ្វើបច្ចុប្បន្នកម្មទិន្នន័យស្ថិតិថាមពល ឱ្យបានត្រឹមត្រូវពិតជាមានសារៈសំខាន់ណាស់សម្រាប់រៀបចំផែនការថាមពល និងគោលនយោបាយថាមពលក្នុងទិសដៅធានា និងរក្សាសន្តិសុខថាមពល និងការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព។ ដូច្នេះ ក្រសួងរ៉ែ និងថាមពល បន្តជំរុញការអភិរក្សថាមពល និងប្រសិទ្ធភាពថាមពលក្នុងគ្រប់វិស័យ ជាពិសេសវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និងលំនៅដ្ឋាន ព្រមទាំងការអភិវឌ្ឍថាមពលកកើតឡើងវិញ និងថាមពលថ្មី។

## ៦.២. ទិសដៅបន្ត

សៀវភៅរបាយកាណ៍ស្ថិតិនិងតារាងតុល្យការថាមពលប្រចាំឆ្នាំ២០២០-២០២១ ជាភាសាជាតិត្រូវបានចងក្រង និងបោះពុម្ពផ្សព្វផ្សាយជាផ្លូវការលើកទី១ ដោយក្រសួងរ៉ែ និងថាមពល មានកិច្ចសហប្រតិបត្តិការជាមួយ UNDP។ សៀវភៅរបាយការណ៍នេះ នឹងត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ និងធ្វើការផ្សព្វផ្សាយជាសាធារណៈតាមរយៈគេហទំព័ររបស់ក្រសួងរ៉ែ និងថាមពល និងធ្វើការរៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីទទួលបន្ទុករៀបចំស្ថិតិថាមពល។

ក្រសួងរ៉ែ និងថាមពលរង់ចាំដោយក្តីសោមនស្សរីករាយនូវរាល់សំណូមពរ ឬមតិយោបល់ពីស្ថាប័នរាជរដ្ឋាភិបាល វិនិយោគិន និងសាធារណជន ដើម្បីកែលម្អឱ្យកាន់តែមានសារប្រយោជន៍សម្រាប់ឆ្លុះបញ្ចាំងស្ថានភាពជាក់ស្តែង។

ក្រុមការងារបច្ចេកទេសអន្តរស្ថាប័នរៀបចំស្ថិតិ និងតុល្យភាពថាមពលដែលបានបង្កើតឡើងក្នុងក្របខ័ណ្ឌនេះត្រូវបន្តអនុវត្ត និងធ្វើបច្ចុប្បន្នកម្មរៀបចំប្រមូលចងក្រងទិន្នន័យស្ថិតិថាមពល ដើម្បីអភិវឌ្ឍ និងបង្កើតតារាងតុល្យភាពថាមពលជាតិជារៀងរាល់ឆ្នាំ។

# ឧបសម្ព័ន្ធទី ១៖ តារាងតុល្យភាពថាមពលកម្ពុជា

## តារាងតុល្យភាពថាមពលកម្ពុជាប្រចាំឆ្នាំ ២០២០

ជាពាន់តោនសមមូលប្រេង ( KTOE )

| ការផ្គត់ផ្គង់និងការប្រើប្រាស់ | ធ្យូងថ្ម | ប្រេងឆៅ | ផលិតផលប្រេង | ឧស្ម័នធម្មជាតិ | នុយក្លេអ៊ែរ | វារីអគ្គិសនី | កំដៅផែនដី/ព្រះអាទិត្យ ។ល។ | ជីវឥន្ធនៈ/សំណល់ | ថាមពលអគ្គិសនី | ថាមពលកម្ដៅ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| ផលិតកម្មដើម | 5 | - | - | - | - | 337 | 25 | 2,058 | - | - | 2,426 |
| ការនាំចូល | 1,626 | 7 | 3,364 | - | - | - | - | - | 328 | - | 5,325 |
| ការនាំចេញ | - | - | - | - | - | - | - | - | - | - | - |
| កន្លែងស្តុកប្រេងនាវាអន្តរជាតិ | - | - | -66 | - | - | - | - | - | - | - | -66 |
| កន្លែងស្តុកប្រេងអាកាសយានអន្តរជាតិ | - | - | -61 | - | - | - | - | - | - | - | -61 |
| ការផ្លាស់ប្តូរស្តុក | -52 | - | - | - | - | - | - | - | - | - | -52 |
| **ការផ្គត់ផ្គង់ថាមពលបឋមសរុប** | **1,579** | **7** | **3,237** | **-** | **-** | **337** | **25** | **2,058** | **328** | **-** | **7,571** |
| ការផ្ទេរ | - | -7 | 12 | - | - | - | - | - | - | - | 5 |
| ភាពខុសគ្នានៃស្ថិតិ | - | - | -0 | - | - | - | - | -0 | 0 | - | -0 |
| រោងចក្រអគ្គិសនី | -1,188 | - | -111 | - | - | -337 | -25 | -15 | 774 | - | -901 |
| រោងចក្រអគ្គិសនីនិងកំដៅ( CHP ) | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រថាមពលកម្ដៅ | - | - | - | - | - | - | - | - | - | - | - |
| ចង្ក្រានស្លដែក | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រផលិតឧស្ម័ន | - | - | - | - | - | - | - | - | - | - | - |
| Coke/pat.fuel/BKB/PB plants | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រចម្រាញ់ប្រេង | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រតេលគីមី | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រពង្រាវឧស្ម័ន | - | - | - | - | - | - | - | - | - | - | - |
| ការបំប្លែងផ្សេងទៀត | - | - | - | - | - | - | - | -146 | - | - | -146 |
| ការប្រើប្រាស់ក្នុងឧស្សាហកម្មថាមពលផ្ទាល់ | - | - | - | - | - | - | - | - | -36 | - | -36 |
| ការបាត់បង់ | - | - | - | - | - | - | - | - | -95 | - | -95 |
| **ការប្រើប្រាស់ថាមពលសរុប** | **391** | **-** | **3,138** | **-** | **-** | **-** | **-** | **1,897** | **971** | **-** | **6,398** |
| **ផ្នែកឧស្សាហកម្ម** | **391** | **-** | **202** | **-** | **-** | **-** | **-** | **1,313** | **365** | **-** | **2,272** |
| ស្លដែកនិងដែកថែប | - | - | - | - | - | - | - | - | - | - | - |
| គីមីនិងតេលគីមី | - | - | - | - | - | - | - | - | - | - | - |
| លោហធាតុមិនមែនដែក | - | - | - | - | - | - | - | - | - | - | - |
| រ៉ែមិនមែនលោហៈ | 386 | - | - | - | - | - | - | - | - | - | 386 |
| បរិក្ខារដឹកជញ្ជូន | - | - | - | - | - | - | - | - | - | - | - |
| គ្រឿងម៉ាស៊ីន | - | - | - | - | - | - | - | - | - | - | - |
| ការជីកយករ៉ែ | - | - | - | - | - | - | - | - | - | - | - |
| អាហារនិងថ្នាំជក់ | - | - | - | - | - | - | - | - | - | - | - |
| ក្រដាស់និងបោះពុម្ព | - | - | - | - | - | - | - | - | - | - | - |
| ឈើនិងផលិតផលឈើ | - | - | - | - | - | - | - | - | - | - | - |
| សំណង់ | - | - | - | - | - | - | - | - | - | - | - |
| វាយនភ័ណ្ឌនិងស្បែក | - | - | 5 | - | - | - | - | 597 | 0 | - | 602 |
| ផ្សេងៗមិនបានបញ្ជាក់ | 6 | - | 197 | - | - | - | - | 717 | 365 | - | 1,284 |
| **ការដឹកជញ្ជូន** | **-** | **-** | **2,305** | **-** | **-** | **-** | **-** | **-** | **0** | **-** | **2,305** |
| អាកាសចរណ៍ក្នុងស្រុក | - | - | 3 | - | - | - | - | - | - | - | 3 |
| ផ្លូវគោក | - | - | 2,229 | - | - | - | - | - | 0 | - | 2,229 |
| ផ្លូវដែក | - | - | 3 | - | - | - | - | - | - | - | 3 |
| ការដឹកជញ្ជូនតាមបំពង់បង្ហូរ | - | - | - | - | - | - | - | - | - | - | - |
| នាវាចរក្នុងស្រុក | - | - | 70 | - | - | - | - | - | - | - | 70 |
| ផ្សេងៗមិនបានបញ្ជាក់ | - | - | - | - | - | - | - | - | - | - | - |
| **ផ្សេងៗ** | **-** | **-** | **499** | **-** | **-** | **-** | **-** | **584** | **606** | **-** | **1,690** |
| លំនៅឋាន | - | - | 128 | - | - | - | - | 584 | 334 | - | 1,046 |
| ពាណិជ្ជកម្មនិងសេវាសាធារណៈ | - | - | 150 | - | - | - | - | - | 273 | - | 423 |
| កសិកម្ម/ព្រៃឈើ | - | - | 143 | - | - | - | - | - | - | - | 143 |
| ការនេសាទ | - | - | 78 | - | - | - | - | - | - | - | 78 |
| ផ្សេងៗមិនបានបញ្ជាក់ | - | - | - | - | - | - | - | - | - | - | - |
| **ការប្រើប្រាស់មិនមែនថាមពល** | **-** | **-** | **131** | **-** | **-** | **-** | **-** | **-** | **-** | **-** | **131** |
| ក្នុងឧស្សាហកម្ម/ការបំប្លែង/ថាមពល | - | - | - | - | - | - | - | - | - | - | - |
| ក្នុងចំនោម: *គីមី/គីមីឥន្ធនៈ* | - | - | - | - | - | - | - | - | - | - | - |
| នៅក្នុងការដឹកជញ្ជូន | - | - | 117 | - | - | - | - | - | - | - | 117 |
| ផ្សេងៗ | - | - | 15 | - | - | - | - | - | - | - | 15 |
| **អគ្គិសនីនិងថាមពលកម្ដៅផលិតបាន** | | | | | | | | | | | |
| **អគ្គិសនីផលិតបាន - GWh** | **4,271** | **-** | **457** | **-** | **-** | **3,918** | **290** | **66** | **-** | **-** | **9,001** |
| រោងចក្រអគ្គិសនី | 4,271 | - | 457 | - | - | 3,918 | 290 | 66 | - | - | 9,001 |
| រោងចក្រអគ្គិសនីនិងកម្ដៅ ( CHP ) | - | - | - | - | - | - | - | - | - | - | - |
| **ថាមពលកម្ដៅផលិតបាន - TJ** | **-** | **-** | **-** | **-** | **-** | **-** | **-** | **-** | **-** | **-** | **-** |
| រោងចក្រអគ្គិសនីនិងកម្ដៅ ( CHP ) | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រផលិតកម្ដៅ ( CHP ) | - | - | - | - | - | - | - | - | - | - | - |

## តារាងតុល្យភាពថាមពលកម្ពុជាប្រចាំឆ្នាំ ២០២១

| ជាពាន់តោនសមមូលប្រេង ( KTOE ) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **ការផ្គត់ផ្គង់និងការប្រើប្រាស់** | ធ្យូងថ្ម | ប្រេងឆៅ | ផលិតផលប្រេង | ឧស្ម័នធម្មជាតិ | នុយក្លេអ៊ែរ | វារីអគ្គិសនី | កំដៅផែនដី/ព្រះអាទិត្យ ។ល។ | ជីវឥន្ធនៈ/សំណល់ | ថាមពលអគ្គិសនី | ថាមពលកម្ដៅ | សរុប |
| ផលិតកម្មដើម | 7 | - | - | - | - | 439 | 53 | 2,137 | - | - | 2,636 |
| ការនាំចូល | 1,437 | 22 | 3,330 | - | - | - | - | - | 291 | - | 5,080 |
| ការនាំចេញ | - | - | - | - | - | - | - | - | - | - | - |
| កន្លែងស្តុកប្រេងនាវាអន្តរជាតិ | - | - | -34 | - | - | - | - | - | - | - | -34 |
| កន្លែងស្តុកប្រេងអាកាសយានអន្តរជាតិ | - | - | -52 | - | - | - | - | - | - | - | -52 |
| ការផ្លាស់ប្តូរស្តុក | -57 | - | - | - | - | - | - | - | - | - | -57 |
| **ការផ្គត់ផ្គង់ថាមពលបឋមសរុប** | **1,387** | **22** | **3,244** | **-** | **-** | **439** | **53** | **2,137** | **291** | **-** | **7,573** |
| ការផ្ទេរ | - | -22 | 40 | - | - | - | - | - | - | - | 17 |
| ភាពខុសគ្នានៃស្ថិតិ | - | - | 1 | - | - | - | - | - | 0 | - | 1 |
| រោងចក្រអគ្គិសនី | -893 | - | -111 | - | - | -439 | -53 | -11 | 869 | - | -638 |
| រោងចក្រអគ្គិសនីនិងកំដៅ( CHP ) | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រថាមពលកម្ដៅ | - | - | - | - | - | - | - | - | - | - | - |
| ចង្ក្រានស្លដែក | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រផលិតឧស្ម័ន | - | - | - | - | - | - | - | - | - | - | - |
| Coke/pat.fuel/BKB/PB plants | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រចម្រាញ់ប្រេង | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រតេលគីមី | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រពង្រាវឧស្ម័ន | - | - | - | - | - | - | - | - | - | - | - |
| ការបំប្លែងផ្សេងទៀត | - | - | - | - | - | - | - | -153 | - | - | -153 |
| ការប្រើប្រាស់ក្នុងឧស្សាហកម្មថាមពលផ្ទាល់ | - | - | - | - | - | - | - | - | -34 | - | -34 |
| ការបាត់បង់ | - | - | - | - | - | - | - | - | -110 | - | -110 |
| **ការប្រើប្រាស់ថាមពលសរុប** | **494** | **-** | **3,175** | **-** | **-** | **-** | **-** | **1,972** | **1,016** | **-** | **6,656** |
| **ផ្នែកឧស្សាហកម្ម** | **494** | **-** | **226** | **-** | **-** | **-** | **-** | **1,390** | **366** | **-** | **2,476** |
| ស្លដែកនិងដែកថែប | - | - | - | - | - | - | - | - | - | - | - |
| គីមីនិងតេលគីមី | - | - | - | - | - | - | - | - | - | - | - |
| លោហធាតុមិនមែនដែក | - | - | - | - | - | - | - | - | - | - | - |
| រ៉ែមិនមែនលោហៈ | 486 | - | - | - | - | - | - | - | - | - | 486 |
| បរិក្ខារដឹកជញ្ជូន | - | - | - | - | - | - | - | - | - | - | - |
| គ្រឿងម៉ាស៊ីន | - | - | - | - | - | - | - | - | - | - | - |
| ការជីកយករ៉ែ | - | - | - | - | - | - | - | - | - | - | - |
| អាហារនិងថ្នាំជក់ | - | - | - | - | - | - | - | - | - | - | - |
| ក្រដាស់និងបោះពុម្ព | - | - | - | - | - | - | - | - | - | - | - |
| ឈើនិងផលិតផលឈើ | - | - | - | - | - | - | - | - | - | - | - |
| សំណង់ | - | - | - | - | - | - | - | - | - | - | - |
| វាយនភ័ណ្ឌនិងស្បែក | - | - | 4 | - | - | - | - | 559 | 0 | - | 564 |
| ផ្សេងៗមិនបានបញ្ជាក់ | 8 | - | 222 | - | - | - | - | 830 | 366 | - | 1,427 |
| **ការដឹកជញ្ជូន** | **-** | **-** | **2,228** | **-** | **-** | **-** | **-** | **-** | **-** | **-** | **2,228** |
| អាកាសចរណ៍ក្នុងស្រុក | - | - | 2 | - | - | - | - | - | - | - | 2 |
| ផ្លូវគោក | - | - | 2,150 | - | - | - | - | - | - | - | 2,150 |
| ផ្លូវដែក | - | - | 4 | - | - | - | - | - | - | - | 4 |
| ការដឹកជញ្ជូនតាមបំពង់បង្ហូរ | - | - | - | - | - | - | - | - | - | - | - |
| នាវាចរក្នុងស្រុក | - | - | 72 | - | - | - | - | - | - | - | 72 |
| ផ្សេងៗមិនបានបញ្ជាក់ | - | - | - | - | - | - | - | - | - | - | - |
| **ផ្សេងៗ** | **-** | **-** | **552** | **-** | **-** | **-** | **-** | **583** | **650** | **-** | **1,785** |
| លំនៅឋាន | - | - | 210 | - | - | - | - | 583 | 364 | - | 1,156 |
| ពាណិជ្ជកម្មនិងសេវាសាធារណៈ | - | - | 128 | - | - | - | - | - | 286 | - | 414 |
| កសិកម្ម/ព្រៃឈើ | - | - | 149 | - | - | - | - | - | - | - | 149 |
| ការនេសាទ | - | - | 66 | - | - | - | - | - | - | - | 66 |
| ផ្សេងៗមិនបានបញ្ជាក់ | - | - | - | - | - | - | - | - | - | - | - |
| **ការប្រើប្រាស់មិនមែនថាមពល** | **-** | **-** | **168** | **-** | **-** | **-** | **-** | **-** | **-** | **-** | **168** |
| ក្នុងឧស្សាហកម្ម/ការបប្លែង/ថាមពល | - | - | - | - | - | - | - | - | - | - | - |
| ក្នុងចំនោម: *គីមី/គីមីឥន្ធនៈ* | - | - | - | - | - | - | - | - | - | - | - |
| នៅក្នុងការដឹកជញ្ជូន | - | - | 168 | - | - | - | - | - | - | - | 168 |
| ផ្សេងៗ | - | - | - | - | - | - | - | - | - | - | - |
| **អគ្គិសនីនិងថាមពលកម្ដៅផលិតបាន** | | | | | | | | | | | |
| **អគ្គិសនីផលិតបាន - GWh** | **3,777** | **-** | **562** | **-** | **-** | **5,107** | **611** | **50** | **-** | **-** | **10,107** |
| រោងចក្រអគ្គិសនី | 3,777 | - | 562 | - | - | 5,107 | 611 | 50 | - | - | 10,107 |
| រោងចក្រអគ្គិសនីនិងកម្ដៅ ( CHP ) | - | - | - | - | - | - | - | - | - | - | - |
| **ថាមពលកម្ដៅផលិតបាន - TJ** | **-** | **-** | **-** | **-** | **-** | **-** | **-** | **-** | **-** | **-** | **-** |
| រោងចក្រអគ្គិសនីនិងកម្ដៅ ( CHP ) | - | - | - | - | - | - | - | - | - | - | - |
| រោងចក្រផលិតកម្ដៅ ( CHP ) | - | - | - | - | - | - | - | - | - | - | - |

# ឧបសម្ព័ន្ធទី ២៖ គម្រូទសំណួរប្រមូលទិន្នន័យថាមពល

## ១. ក្រសួងរ៉ែ និងថាមពល

### ១.១. អគ្គនាយកដ្ឋានថាមពល

| បរិយាយឈ្មោះទិន្នន័យ (GDE) | ខ្នាត | ឆ្នាំ...... |
|---|---|---|
| បរិមាណធ្យូងថ្ម ប្រភេទ "Bituminous" ដែលប្រើប្រាស់ក្នុងរោងចក្រផលិតកម្តៅឬចំហាយទឹក | តោន | |
| បរិមាណធ្យូងថ្ម ប្រភេទ "Sub-bituminous" ដែលប្រើប្រាស់ក្នុងរោងចក្រផលិតកម្តៅឬចំហាយទឹក | តោន | |
| បរិមាណធ្យូងថ្ម ប្រភេទ "Lignite" ដែលប្រើប្រាស់ក្នុងរោងចក្រផលិតកម្តៅឬចំហាយទឹក | តោន | |
| បរិមាណឥន្ទនៈ "អុស" ប្រើប្រាស់ជាមធ្យម | គក/ផ្ទះ/ឆ្នាំ | |
| បរិមាណឥន្ទនៈ "ធ្យូង" ប្រើប្រាស់ជាមធ្យម | *គក/ផ្ទះ/ឆ្នាំ* | |
| បរិមាណឥន្ទនៈ "ឧស្ម័នហ្គាស" ប្រើប្រាស់ជាមធ្យម | *គក/ផ្ទះ/ឆ្នាំ* | |
| បរិមាណអុសដែលបានផ្គត់ផ្គង់ ដើម្បីផលិតជាធ្យូង | តោន | |

## ១.២. អគ្គនាយកដ្ឋានប្រេងកាត

| បរិយាយឈ្មោះទិន្នន័យ ( GDP ) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| ស្តុកប្រេង ប្រភេទ "Crude Oil" | តោន | |
| ស្តុកប្រេង ប្រភេទ "LPG" | តោន | |
| ស្តុកប្រេង ប្រភេទ "ប្រេងសាំង" | តោន | |
| ស្តុកប្រេង ប្រភេទ "ប្រេងយន្តហោះ" | តោន | |
| ស្តុកប្រេង ប្រភេទ "ប្រេងម៉ាស៊ូត" | តោន | |
| ស្តុកប្រេង ប្រភេទ "ប្រេងខ្មៅ" | តោន | |
| ស្តុកប្រេង ប្រភេទ "ប្រេងរំអិល" | តោន | |

## ១.៣. អគ្គនាយកដ្ឋានធនធានរ៉ែ

| បរិយាយឈ្មោះទិន្នន័យ (GDM) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| បរិមាណធ្យូងថ្ម ប្រភេទ "Lignite" ដែលផលិតក្នុងប្រទេស | តោន | |
| បរិមាណធ្យូងថ្ម ប្រភេទ "Bituminous" នាំចូល ដែលប្រើប្រាស់ក្នុងរោងចក្រផលិតស៊ីម៉ង់ត៍ | តោន | |
| បរិមាណធ្យូងថ្ម ប្រភេទ "Sub-bituminous" នាំចូល ដែលប្រើប្រាស់ក្នុងរោងចក្រផលិតស៊ីម៉ង់ត៍ | តោន | |
| បរិមាណធ្យូងថ្ម ប្រភេទ "Lignite" ក្នុងស្រុក ដែលប្រើប្រាស់ក្នុងរោងចក្រស៊ីម៉ង់ត៍ | តោន | |
| បរិមាណធ្យូងថ្ម ប្រភេទ "Lignite" ក្នុងស្រុក ដែលប្រើប្រាស់ក្នុងរោងចក្រផ្សេងទៀត | តោន | |
| ស្តុក ធ្យូងថ្ម ប្រភេទ "Sub-bituminous" ដែលប្រើប្រាស់ក្នុងរោងចក្រអគ្គិសនី | តោន | |

## ២. អគ្គិសនីកម្ពុជា

| បរិយាយឈ្មោះទិន្នន័យ (EDC) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| បរិមាណធ្យូងថ្ម ប្រភេទ "Bituminous" ដែលប្រើប្រាស់ក្នុងរោងចក្រផលិតអគ្គិសនី | តោន | |
| បរិមាណធ្យូងថ្ម ប្រភេទ "Sub-bituminous" ដែលប្រើប្រាស់ក្នុងរោងចក្រផលិតអគ្គិសនី | តោន | |
| បរិមាណប្រេង ប្រភេទ "Gas/ Diesel" ដែលប្រើប្រាស់ក្នុងរោងចក្រផលិតអគ្គិសនី | តោន | |
| បរិមាណប្រេង ប្រភេទ "Fuel Oil" ដែលប្រើប្រាស់ក្នុងរោងចក្រផលិតអគ្គិសនី | តោន | |
| បរិមាណអគ្គិសនីដែលផលិតចេញពីជីវម៉ាសប្រភេទ "អុស ឬកាកសំណល់ពីអុស" | kWh | |
| អំណាចកម្តៅនៃជីវម៉ាស ប្រភេទ "អុស ឬកាកសំណល់ពីអុស" ដែលប្រើប្រាស់សម្រាប់ផលិតអគ្គិសនី (បើមាន) | MJ/kg | |
| បរិមាណអគ្គិសនីដែលផលិតចេញពីជីវម៉ាសប្រភេទ " កាកសំណល់កសិ-ឧស្សាហកម្ម" ឧ. កាកអំពៅ | kWh | |
| អំណាចកម្តៅនៃជីវម៉ាស ប្រភេទ "កាកសំណល់កសិ-ឧស្សាហកម្ម" ដែលប្រើប្រាស់សម្រាប់ផលិតអគ្គិសនី ឧ. កាកអំពៅ (បើមាន) | MJ/kg | |

## ៣. អាជ្ញាធរអគ្គិសនីកម្ពុជា

| បរិយាយឈ្មោះទិន្នន័យ (EAC) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| **បរិមាណអគ្គិសនីដែលផលិតសរុប (Energy as generated)** | GWh | |
| អគ្គិសនីដែលផលិតសរុប ប្រភពពី វារីអគ្គិសនី (Hydro) | GWh | |
| អគ្គិសនីដែលផលិតសរុប ប្រភពពី សូឡា (Solar) | GWh | |
| អគ្គិសនីដែលផលិតសរុប ប្រភពពី ជីវម៉ាស (Biomass) | GWh | |
| អគ្គិសនីដែលផលិតសរុប ប្រភពពី ប្រេងខ្មៅ (HFO) និងប្រេងម៉ាស៊ូត | GWh | |
| អគ្គិសនីដែលផលិតសរុប ប្រភពពី ធ្យូងថ្ម (Coal) | GWh | |
| អគ្គិសនីដែលផលិតសរុប ប្រភពពី ឧស្ម័នធម្មជាតិ (LNG) | GWh | |
| **បរិមាណអគ្គិសនីដែលបញ្ជូនចេញ (Energy as sent/delivered)** | GWh | |
| *បរិមាណអគ្គិសនីដែលផ្គត់ផ្គង់សរុប ប្រភពពី វារីអគ្គិសនី (Hydro)* | GWh | |

| បរិយាយឈ្មោះទិន្នន័យ (EAC) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| *បរិមាណអគ្គិសនីដែលផ្គត់ផ្គង់សរុប ប្រភពពី សូឡា (Solar)* | GWh | |
| *បរិមាណអគ្គិសនីដែលផ្គត់ផ្គង់សរុប ប្រភពពី ជីវម៉ាស (Biomass)* | GWh | |
| *បរិមាណអគ្គិសនីដែលផ្គត់ផ្គង់សរុប ប្រភពពី ប្រេងខ្មៅ (HFO) និងប្រេងម៉ាស៊ូត* | GWh | |
| *បរិមាណអគ្គិសនីដែលផ្គត់ផ្គង់សរុប ប្រភពពី ធ្យូងថ្ម (Coal)* | GWh | |
| *បរិមាណអគ្គិសនីដែលផ្គត់ផ្គង់សរុប ប្រភពពី ឧស្ម័នធម្មជាតិ (LNG)* | GWh | |
| **បរិមាណអគ្គិសនីដែលប្រើប្រាស់ដោយរោងចក្រអគ្គិសនីខ្លួនឯង** (*Energy own use*) | GWh | |
| *អគ្គិសនីដែលប្រើប្រាស់ខ្លួនឯង ចំពោះប្រភពពី វារីអគ្គិសនី (Hydro)* | GWh | |
| *អគ្គិសនីដែលប្រើប្រាស់ខ្លួនឯង ចំពោះប្រភពពី សូឡា (Solar)* | GWh | |
| *អគ្គិសនីដែលប្រើប្រាស់ខ្លួនឯង ចំពោះប្រភពពី ជីវម៉ាស (Biomass)* | GWh | |
| *អគ្គិសនីដែលប្រើប្រាស់ខ្លួនឯង ចំពោះប្រភពពី ប្រេងខ្មៅ (HFO) និងប្រេងម៉ាស៊ូត* | GWh | |

| បរិយាយឈ្មោះទិន្នន័យ (EAC) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| *អគ្គិសនីដែលប្រើប្រាស់ខ្លួនឯង ចំពោះប្រភពពី ធ្យូងថ្ម (Coal)* | GWh | |
| *អគ្គិសនីដែលប្រើប្រាស់ខ្លួនឯង ចំពោះប្រភពពី ឧស្ម័នធម្មជាតិ (LNG)* | GWh | |
| **បរិមាណអគ្គិសនីនាំចូលសរុប** | GWh | |
| **បរិមាណអគ្គិសនីដែលបានលក់អោយអ្នកប្រើប្រាស់** | GWh | |
| *១-បរិមាណអគ្គិសនីសរុបដែលប្រើប្រាស់លើបណ្តាញសាធារណៈក្នុងវិស័យអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ឧស្សាហកម្មតូចៗ និងរដ្ឋបាល* | GWh | |
| *២- បរិមាណអគ្គិសនីសរុបដែលប្រើប្រាស់ធុនធំ និងមធ្យម ក្នុងវិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម (2)* | GWh | |
| *៣- បរិមាណអគ្គិសនីសរុបដែលប្រើប្រាស់តាមពេលវេលា ក្នុងវិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម* | GWh | |
| *៤- បរិមាណអគ្គិសនីសរុបដែលប្រើប្រាស់ក្នុងសាលារៀន មណ្ឌលសុខភាព និងមន្ទីរពេទ្យនៅជនបទ* | GWh | |
| *៥- បរិមាណអគ្គិសនីសរុបដែលប្រើប្រាស់ក្នុងវិស័យលំនៅដ្ឋាន គ្រប់ប្រភេទ* | GWh | |

| បរិយាយឈ្មោះទិន្នន័យ (EAC) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| ៦-បរិមាណអគ្គិសនីសរុបដែលប្រើប្រាស់ក្នុងវិស័យដឹកជញ្ជូន គ្រប់ប្រភេទ | GWh | |
| ៨-បរិមាណអគ្គិសនីសរុបដែលប្រើប្រាស់ក្នុងវិស័យកសិកម្ម គ្រប់ប្រភេទ | GWh | |
| **ការបាត់បង់អគ្គិសនី** | GWh | |

## ៤. អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| បរិយាយឈ្មោះទិន្នន័យ (GDCE) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| បរិមាណថ្មផ្សេងៗ ប្រភេទ "ប៊ីទូមីនីស" ដែលនាំចូលក្នុងប្រទេស | តោន | |
| បរិមាណថ្មផ្សេងៗ ប្រភេទ "សាប់ប៊ីទូមីនីស" ដែលនាំចូលក្នុងប្រទេស | តោន | |
| បរិមាណថ្មផ្សេងៗ ប្រភេទ "លីហ្គណាយថ៍" ដែលនាំចូលក្នុងប្រទេស | តោន | |
| បរិមាណប្រេង ប្រភេទ "ប្រេងឆៅ" ដែលនាំចូលក្នុងប្រទេស | តោន | |
| បរិមាណប្រេង ប្រភេទ "ហ្គាស LPG" ដែលនាំចូលក្នុងប្រទេស | តោន | |
| បរិមាណប្រេង ប្រភេទ "ប្រេងសាំង" ដែលនាំចូលក្នុងប្រទេស | តោន | |
| បរិមាណប្រេង ប្រភេទ "ប្រេងយន្តហោះ" ដែលនាំចូលក្នុងប្រទេស | តោន | |
| បរិមាណប្រេង ប្រភេទ "ប្រេងម៉ាស៊ូត" ដែលនាំចូលក្នុងប្រទេស | តោន | |
| បរិមាណប្រេង ប្រភេទ "ប្រេងខ្មៅ" ដែលនាំចូលក្នុងប្រទេស | តោន | |

| បរិយាយឈ្មោះទិន្នន័យ (GDCE) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| បរិមាណប្រេង ប្រភេទ "ប្រេងរំអិល" ដែលនាំចូលក្នុងប្រទេស | តោន | |
| បរិមាណប្រេង ប្រភេទ "កៅស៊ូក្រាល់ថ្នល់" ដែលនាំចូលក្នុងប្រទេស | តោន | |
| បរិមាណប្រេង ប្រភេទ "សារធាតុបន្ថែមក្នុងឥន្ធនៈ (MTBE)" ដែលនាំចូលក្នុងប្រទេស | តោន | |
| បរិមាណធ្យូងថ្ម ប្រភេទ "Bituminous" ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណធ្យូងថ្ម ប្រភេទ "Sub-bituminous" ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណធ្យូងថ្ម ប្រភេទ "Lignite" ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណធ្យូងថ្ម ប្រភេទ "..............................." ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណប្រេង ប្រភេទ "Crude Oil" ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណប្រេង ប្រភេទ "LPG" ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណប្រេង ប្រភេទ "Motor Gasoline" ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |

| បរិយាយឈ្មោះទិន្នន័យ (GDCE) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| បរិមាណប្រេង ប្រភេទ "Gasoline Jet Fuel" ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណប្រភេទ "Gas/Diesel" ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណប្រេង ប្រភេទ "Fuel Oil" ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណប្រេង ប្រភេទ "Lubricants" ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណប្រេង ប្រភេទ "Bitumen" ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណប្រេង ប្រភេទផ្សេងទៀត "..........................." ដែលនាំចេញពីប្រទេសកម្ពុជា | តោន | |
| បរិមាណជីវម៉ាសនាំចេញសរុប (បញ្ជាក់ប្រភេទជីវម៉ាស៖ ____________________) | តោន | |

## ៥. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

| បរិយាយឈ្មោះទិន្នន័យ (MISTI) | ខ្នាត | ឆ្នាំ....... |
| --- | --- | --- |
| **ចំនួនឡចំហាយសរុប ដែលប្រើប្រាស់អុស (ក្នុងវិស័យកាត់ដេរ)** | ចំនួនឡ | |
| **ចំនួនឡចំហាយសរុប ដែលប្រើប្រាស់ ជីវម៉ាសផ្សេងទៀតក្រៅពីអុស (ក្នុងវិស័យកាត់ដេរ)** | ចំនួនឡ | |
| **ជីវម៉ាសដែលប្រើប្រាស់ក្នុងឧស្សាហកម្មផ្សេងទៀត(ក្រៅពីវិស័យកាត់ដេរ)** | | |
| *តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្ម* | លានដុល្លារ | |
| *បរិមាណជីវម៉ាសដែលប្រើប្រាស់ដោយឡចំហាយ (ក្នុងវិស័យកាត់ដេរ)* | តោន | |
| *តម្លៃបន្ថែមបានមកពីអនុវិស័យឧស្សាហកម្មផ្សេងទៀត ក្រៅពីវិស័យកាត់ដេរ)* | លានដុល្លារ | |
| **ការប៉ាន់ស្មានបរិមាណថាមពលដែលប្រើប្រាស់** | តោន/ឆ្នាំ | |
| *ចំនួនឡចំហាយសរុប ដែលប្រើប្រាស់ ប្រេងខ្មៅ* | ចំនួនឡ | |
| **ការប៉ាន់ស្មានបរិមាណថាមពលដែលប្រើប្រាស់** | តោន/ឆ្នាំ | |

| បរិយាយឈ្មោះទិន្នន័យ ( MISTI ) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| *ចំនួនឡចំហាយសរុប ដែលប្រើប្រាស់ ប្រេងម៉ាស៊ូត* | ចំនួនឡ | |
| **ការប៉ាន់ស្មានបរិមាណថាមពលដែលប្រើប្រាស់** | តោន/ឆ្នាំ | |
| *ចំនួនឡចំហាយសរុប ដែលប្រើប្រាស់ ឧស្ម័នLPG* | ចំនួនឡ | |
| **បរិមាណប្រេងម៉ាស៊ូត មិនមែនសម្រាប់ផលិតចំហាយ ក្នុងអនុវិស័យឧស្សាហកម្មផ្សេងទៀត** | | |
| *តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្ម* | លានដុល្លារ | |
| **ការប៉ាន់ស្មានបរិមាណថាមពលដែលប្រើប្រាស់** | តោនធ្យូងថ្ម/ឆ្នាំ | |
| *ចំនួនឡចំហាយសរុប ដែលប្រើប្រាស់ធ្យូងថ្ម* | ចំនួនឡ | |
| **បរិមាណស៊ីម៉ង់ត៍ដែលផលិត** | តោន/ឆ្នាំ | |
| **ការប៉ាន់ស្មានបរិមាណថាមពលដែលប្រើប្រាស់** | kWh/ឆ្នាំ | |
| *ចំនួនឡចំហាយសរុប ដែលប្រើប្រាស់ថាមពលអគ្គិសនី* | ចំនួនឡ | |

| បរិយាយឈ្មោះទិន្នន័យ ( MISTI ) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| ចំនួនឡចំហាយសរុប ដែលប្រើប្រាស់ សំណល់ក្រណាត់ | ចំនួនឡ | |
| ចំនួនឡចំហាយសរុប ដែលប្រើប្រាស់សំណល់កំដៅឡើងវិញ ( Waste heat recovery ) | ចំនួនឡ | |

## ៦. វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

| បរិយាយឈ្មោះទិន្នន័យ ( NIS ) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| ចំនួនប្រជាជន នៅតំបន់ប្រជុំជន | នាក់ | |
| ចំនួនប្រជាជន នៅតំបន់ជនបទ | នាក់ | |
| ចំនួនប្រជាជន សរុប | នាក់ | |
| អត្រាកំណើនប្រជាជន | ភាគរយ | |
| ចំនួនលំនៅដ្ឋាន នៅតំបន់ប្រជុំជន | ខ្នងផ្ទះ | |
| ចំនួនលំនៅដ្ឋាន នៅតំបន់ជនបទ | ខ្នងផ្ទះ | |

| បរិយាយឈ្មោះទិន្នន័យ (NIS) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| ចំនួនលំនៅដ្ឋាន (សរុបនៅកម្ពុជា) | ខ្នងផ្ទះ | |
| ចំនួនមនុស្សក្នុងលំនៅដ្ឋាន (មធ្យមភាគកម្ពុជា) | នាក់/ខ្នងផ្ទះ | |
| **ការប៉ាន់ស្មានបរិមាណថាមពលដែលប្រើប្រាស់** | | |
| *សមាមាត្រលំនៅដ្ឋានដែលចម្អិនអាហារ ដោយឥន្ធនៈ "អុស" (មធ្យមភាគកម្ពុជា) នៅតំបន់ជនបទ* | ភាគរយ | |
| **ការប៉ាន់ស្មានបរិមាណធ្យូងដែលប្រើប្រាស់** | kg | |
| *សមាមាត្រលំនៅដ្ឋានដែលចម្អិនអាហារ ដោយឥន្ធនៈ "ធ្យូង" (មធ្យមភាគកម្ពុជា)* | ភាគរយ | |
| **ការប៉ាន់ស្មានបរិមាណថាមពល LPG ដែលប្រើប្រាស់** | តោន | |
| *សមាមាត្រលំនៅដ្ឋានដែលចម្អិនអាហារ ដោយឥន្ធនៈ "ឧស្ម័នហ្គាស" (មធ្យមភាគកម្ពុជា)* | ភាគរយ | |

## ៧. ក្រសួងសាធារណការ និងដឹកជញ្ជូន

| បរិយាយឈ្មោះទិន្នន័យ (MPWT) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| បរិមាណប្រេងម៉ាស៊ូតដែលប្រើប្រាស់ ក្នុងវិស័យដឹកជញ្ជូនផ្លូវដែក | តោន | |
| បរិមាណប្រេងម៉ាស៊ូតដែលប្រើប្រាស់ ក្នុងវិស័យដឹកជញ្ជូនផ្លូវទឹកក្នុងស្រុក | តោន | |
| បរិមាណប្រេងខ្មៅប្រើប្រាស់ដោយវិស័យនាវាចរ | តោន | |
| បរិមាណប្រេងប្រើប្រាស់សម្រាប់ដឹកជញ្ជូននាវាជំនួញសមុទ្រ (អន្តរជាតិ) | តោន | |
| បរិមាណប្រេងប្រើប្រាស់សម្រាប់ដឹកជញ្ជូនផ្លូវទឹក (ក្នុងស្រុក) | លីត្រ | |
| *ចំនួនជលយានដែលបានចុះបញ្ជី និងកំពុងប្រើប្រាស់* | គ្រឿង | |
| *ចំងាយដែលបានធ្វើដំណើរដោយជលយាននីមួយៗក្នុងមួយឆ្នាំ* | km | |
| *ថាមពលជាមធ្យមដែលប្រើប្រាស់ដំណើរដោយជលយាននីមួយៗ* | លីត្រ/km | |
| វិស័យដឹកជញ្ជូនផ្លូវគោក (ចុះបញ្ជី) | | |

| បរិយាយឈ្មោះទិន្នន័យ (MPWT) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| **យានយន្តប្រើប្រាស់ប្រេងសាំង** | | |
| *ចំនួនទោចក្រយានយន្តសរុប* | គ្រឿង | |
| *ចំនួនត្រីចក្រយានយន្ត (ម៉ូតូកង់បី) សរុប* | គ្រឿង | |
| *ចំនួនរថយន្តគ្រួសារសរុប* | គ្រឿង | |
| *ចំនួនរថយន្តPick-up សរុប* | គ្រឿង | |
| *ចំនួនរថយន្តក្រុងខ្នាតតូចសរុប* | គ្រឿង | |
| **យានយន្តប្រើប្រាស់ប្រេងម៉ាស៊ូត** | | |
| *ចំនួនរថយន្តគ្រួសារសរុប* | គ្រឿង | |
| *ចំនួនរថយន្តPick-up សរុប* | គ្រឿង | |
| *ចំនួនរថយន្តក្រុងខ្នាតតូចសរុប* | គ្រឿង | |

| បរិយាយឈ្មោះទិន្នន័យ (MPWT) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| *ចំនួនរថយន្តក្រុងសរុប* | គ្រឿង | |
| *ចំនួនរថយន្តដឹកទំនិញសរុប* | គ្រឿង | |
| **យានយន្តប្រើប្រាស់អគ្គិសនី** | | |
| *ចំនួនទោចក្រយានយន្តសរុប* | គ្រឿង | |
| *ចំនួនត្រីចក្រយានយន្ត(ម៉ូតូកង់បី) សរុប* | គ្រឿង | |
| *ចំនួនរថយន្តគ្រួសារសរុប* | គ្រឿង | |
| *ចំនួនរថយន្តPick-up សរុប* | គ្រឿង | |
| *ចំនួនរថយន្តក្រុងខ្នាតតូចសរុប* | គ្រឿង | |
| *ចំនួនរថយន្តក្រុងសរុប* | គ្រឿង | |
| **យានយន្តប្រើប្រាស់ឧស្ម័ន LPG** | | |

| បរិយាយឈ្មោះទិន្នន័យ (MPWT) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| *ចំនួនត្រីចក្រយានយន្ត (ម៉ូតូកង់បី) សរុប* | គ្រឿង | |
| *ចំនួនរថយន្តគ្រួសារសរុប* | គ្រឿង | |
| *ចំនួនរថយន្តក្រុងសរុប* | គ្រឿង | |

## ៨. វត្តលេខាធិការដ្ឋានអាកាសចរស៊ីវិល

| បរិយាយឈ្មោះទិន្នន័យ (SSCA) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| បរិមាណ ហ្គាស ដែលប្រើប្រាស់ | លីត្រ | |
| បរិមាណ ប្រេងសាំង ដែលប្រើប្រាស់ | លីត្រ | |
| បរិមាណ ប្រេងយន្តហោះ ដែលប្រើប្រាស់ | លីត្រ | |
| បរិមាណ ប្រេងម៉ាស៊ូត ដែលប្រើប្រាស់ | លីត្រ | |
| បរិមាណ ប្រេងរំអិល ដែលប្រើប្រាស់ | លីត្រ | |
| បរិមាណ ប្រេងយន្តហោះ ដែលប្រើប្រាស់ (សម្រាប់ការហោះហើរក្នុងស្រុក) | លីត្រ | |

## ៩. ក្រសួងទេសចរណ៍

| បរិយាយឈ្មោះទិន្នន័យ (MOT) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| សណ្ឋាគារ | ចំនួន ឬផ្ទៃក្រឡា | |
| ផ្ទះសំណាក់ | ចំនួន ឬផ្ទៃក្រឡា | |
| ភោជនីយដ្ឋាន | ចំនួន ឬផ្ទៃក្រឡា | |
| ម៉ាស្សា និង ស្ប៉ា | ចំនួន ឬផ្ទៃក្រឡា | |
| ខារ៉ាអូខេ | ចំនួន ឬផ្ទៃក្រឡា | |
| រីសតថ៍ | ចំនួន ឬផ្ទៃក្រឡា | |
| ហាងអនុស្សាវរីយ៍ | ចំនួន ឬផ្ទៃក្រឡា | |

## ១០. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| បរិយាយឈ្មោះទិន្នន័យ (MLMUPC) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| ក្រឡាផ្ទៃនៃអគារសំណង់ដែលកំពុងប្រើប្រាស់ (គិតចាប់ពីឆ្នាំ២០០០) | $m^2$ | |
| *ប្រភេទការិយាល័យ* | $m^2$ | |
| *ប្រភេទផ្សារទំនើប (Retail)* | $m^2$ | |
| *ប្រភេទសណ្ឋាគារ* | $m^2$ | |
| *ប្រភេទកន្លែងថែទាំសុខភាព (Healthcare)* | $m^2$ | |
| *ប្រភេទមណ្ឌលអប់រំ (Education)* | $m^2$ | |
| *ប្រភេទឃ្លាំងរក្សាទំនិញ (Warehouse)* | $m^2$ | |
| *ប្រភេទអគារសាធារណៈ (Public buildings)* | $m^2$ | |

## ១១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| បរិយាយឈ្មោះទិន្នន័យ (MAFF) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| **អនុវិស័យដំណាំ** | | |
| បរិមាណអុស ដែលបានពីចំការកៅស៊ូ ស្វាយចន្ទី .... | តោន | |
| ទំហំផ្ទៃដី ចំការកៅស៊ូ ស្វាយចន្ទី .... | ហត | |
| បរិមាណអុស ដែលបានពីចំការកៅស៊ូ ស្វាយចន្ទី ... | តោន/ហត | |
| បរិមាណសំណល់កសិកម្ម (កាកអំពៅ អង្កាម ត្រឡោកដូង ...) | តោន | |
| ទំហំផ្ទៃដីស្រែសរុប កំពុងប្រើប្រាស់ម៉ូទ័របូមទឹកអគ្គិសនី | ហត | |
| ទិន្នផលស្រូវសរុប | តោន | |
| *បរិមាណអង្កាម ដែលបានពីស្រូវ១តោន* | គក | |
| *ទំហំផ្ទៃដីស្រែសរុប ដែលកំពុងបង្កបង្កើនផល* | ហត | |

| បរិយាយឈ្មោះទិន្នន័យ (MAFF) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| *ទំហំផ្ទៃដីចំការសរុប ដែលកំពុងបង្កបង្កើនផល* | ហត | |
| **អនុវិស័យព្រៃឈើ** | | |
| បរិមាណប្រេងសរុបដែលប្រើប្រាស់ | | |
| **អនុវិស័យចិញ្ចឹមសត្វ និងជលផល** | | |
| បរិមាណលាមកសត្វ | តោន | |
| ចំនួនសត្វចតុបាត (គោ ក្របី ជ្រូក...) | ក្បាល | |
| លាមកសត្វ | គក/ក្បា/ឆ្នាំ | |
| បរិមាណអគ្គិសនីសរុបដែលប្រើប្រាស់ក្នុងវិស័យកសិកម្ម (បូមទឹក វារីវប្បកម្ម កសិដ្ឋាន...) | | |
| ចំនួនកសិដ្ឋាន (ដំណាំ និងចិញ្ចឹមសត្វ) កំពុងប្រើប្រាស់អគ្គិសនី | | |
| ចំនួនវារីវប្បកម្ម កំពុងប្រើប្រាស់អគ្គិសនី | | |

| បរិយាយឈ្មោះទិន្នន័យ (MAFF) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| ទិន្នផលវារីវប្បកម្មសរុបប្រចាំឆ្នាំ | | |
| ទិន្នផលកសិដ្ឋាន (ដំណាំ និងចិញ្ចឹមសត្វ) សរុបប្រចាំឆ្នាំ | | |
| ចំនួនយានយន្តកសិកម្ម និងប្រភេទឥន្ធនៈតាមប្រភេទយានយន្ត | ចំនួនម៉ាស៊ីន | |
| ប្រភេទយានយន្តកសិកម្ម ប្រើប្រាស់តាមកសិកម្ម ព្រៃឈើ នេសាទ | ភាគរយ | |
| ចំនួនត្រាក់ទ័រ ម៉ាស៊ីនបូមទឹក ម៉ាស៊ីនច្រូត ម៉ាស៊ីនកិនស្រូវ | ចំនួនម៉ាស៊ីន | |
| បរិមាណប្រេងសរុបដែលប្រើប្រាស់ជាមធ្យមក្នុងមួយឆ្នាំ សម្រាប់ត្រាក់ទ័រ ម៉ាស៊ីនបូមទឹក ម៉ាស៊ីនច្រូត ម៉ាស៊ីនកិនស្រូវ | លីត្រ/ឆ្នាំ | |
| ចំនួនទូកនេសាទ ដែលប្រើប្រាស់ | ចំនួនទូក | |
| បរិមាណប្រេងសរុបដែលប្រើប្រាស់ជាមធ្យមក្នុងមួយឆ្នាំ សម្រាប់ទូកនេសាទ | តោន | |
| **តម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម** | ពាន់លានរៀល | |
| **បរិមាណប្រេងម៉ាស៊ូតដែលប្រើប្រាស់ ក្នុងអនុវិស័យដំណាំ និងកៅស៊ូ** | toe | |

| បរិយាយឈ្មោះទិន្នន័យ (MAFF) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| *តម្លៃបន្ថែមបានមកពីអនុវិស័យដំណាំ និងកៅស៊ូ* | ពាន់លានរៀល | |
| **បរិមាណប្រេងម៉ាស៊ូតដែលប្រើប្រាស់ក្នុងអនុវិស័យ បសុសត្វ និងបក្សី** | toe | |
| *តម្លៃបន្ថែមបានមកពីអនុវិស័យ បសុសត្វ និងបក្សី* | ពាន់លានរៀល | |
| **បរិមាណប្រេងម៉ាស៊ូតដែលប្រើប្រាស់ក្នុងអនុវិស័យ ជលផល** | toe | |
| *តម្លៃបន្ថែមបានមកពីអនុវិស័យ ជលផល* | ពាន់លានរៀល | |
| **បរិមាណប្រេងម៉ាស៊ូតដែលប្រើប្រាស់ក្នុងអនុវិស័យ ព្រៃឈើ** | toe | |
| *តម្លៃបន្ថែមបានមកពីអនុវិស័យ ព្រៃឈើ* | ពាន់លានរៀល | |
| **បរិមាណជីវឧស្ម័ន** | | |
| ***ឡជីវឧស្ម័នលក្ខណៈគ្រួសារ (ទំហំក្រោម៥០ម៣)*** | MJ | |
| *ចំនួនឡជីវឧស្ម័ន (កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ)* | ឡ | |

| បរិយាយឈ្មោះទិន្នន័យ (MAFF) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| *ចំនួនឡជីវឧស្ម័ន (គម្រោងសាងសង់ឡជីវឧស្ម័នកម្ពុជា -ចិន)* | ឡ | |
| *ចំនួនឡជីវឧស្ម័ន (គម្រោងខ្សែសង្វាក់ផលិតកម្មដោយភាពធន់:បរិស្ថាន - ADB)* | ឡ | |
| *ទំហំឡជាមធ្យម* | ម៣/ឡ | |

## ១២. ក្រសួងបរិស្ថាន

| បរិយាយឈ្មោះទិន្នន័យ (MOE) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| *គំរបផ្ទៃដីព្រៃឈើសរុបទូទាំងប្រទេស (ទាំងព្រៃការពារ និងផលិតកម្ម)* | ហត | |
| *ទិន្នផលឈើជាមធ្យម ក្នុងព្រៃមួយហិកតា* | តោន/ហត | |
| *អត្រាបាត់បង់ព្រៃឈើប្រចាំឆ្នាំ* | % | |
| *សមាមាត្រដែលឈើត្រូវបានដកហូតជាអុស* | % | |

## ១៣. ក្រសួងពាណិជ្ជកម្ម

| បរិយាយឈ្មោះទិន្នន័យ (MOC) | ខ្នាត | ឆ្នាំ....... |
|---|---|---|
| សន្និធិពាណិជ្ជកម្ម ប្រភេទ "LPG" | តោន | |
| សន្និធិពាណិជ្ជកម្ម ប្រភេទ "ប្រេងសាំង" | តោន | |
| សន្និធិពាណិជ្ជកម្ម ប្រភេទ "ប្រេងយន្តហោះ" | តោន | |
| សន្និធិពាណិជ្ជកម្ម ប្រភេទ "ប្រេងម៉ាស៊ូត" | តោន | |
| សន្និធិពាណិជ្ជកម្ម ប្រភេទ "ប្រេងខ្មៅ" | តោន | |
| សន្និធិពាណិជ្ជកម្ម ប្រភេទ "ប្រេងរំអិល" | តោន | |

# ឯកសារយោង


១. Draft report on Cambodia National Clean and Efficient Cooking Strategy and Plan 2023-2030-FINAL

២. អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា

៣. ស្ថិតិដឹកជញ្ជូនតាមផ្លូវដែក ឆ្នាំ២០២០-២០២១

៤. របាយការណ៍ប្រចាំឆ្នាំ២០១៩ និងទិសដៅបន្តរបស់ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់

៥. របាយការណ៍ប្រចាំឆ្នាំ២០២០ និងទិសដៅបន្តរបស់ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់

៦. របាយការណ៍ប្រចាំឆ្នាំ២០២១ និងទិសដៅបន្តរបស់ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់

៧. Cambodia Forest Cover 2018

៨. ប្រកាសលេខ១៤៩ អវង ប្រក

៩. Efficient Cookstoves to mitigate global warming and contribute to poverty alleviation in Cambodia.

១០. Cambodia Petroleum Master Plan 2022-2040

១១. Sugar Cane Bagasse Energy Cogeneration – Lessons from Mauritius

១២. Annual Report 2021

១៣. Case study on implementation of the increase of the boiler efficiency by good operational practices in food and beverage industry in Cambodia

១៤. Energy Audit Report: [Confidential name] Garment Factory

១៥. Cambodia: Input-Output Economic Indicators

១៦. Cambodia Energy Balances

១៧. Data Collection of Boilers

១៨. Resource Efficiency and Cleaner Production Strategy and Action Plan 2021-2030
១៩. E-mobility roadmap development of Cambodia
២០. National Energy Efficiency Policy (NEEP) 2022-2030
២១. Final report Feasibility study EE in Industrial sectors
២២. Business Case Study, IEEC Sky High (Cambodia) Co, Ltd, Phnom Penh, Cambodia
២៣. CAMBODIA Beyond Connections Energy Access Diagnostic Report Based on the Multi-Tier Framework
២៤. Energy Statistics Data Browser
២៥. Energy Demand and Supply of Cambodia 2010-2018
២៦. របាយការណ៍បូកសរុបការងារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ២០២០
២៧. របាយការណ៍បូកសរុបការងារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ ២០២១
២៨. Measuring small-scale biogas capacity and production

**ក្រសួងរ៉ែ និងថាមពល**
លេខ៩១ មហាវិថីព្រះនរោត្តម ១២០២១១
ទូរស័ព្ទ៖ (៨៥៥) ២៣ ២១៩ ៥៧៤
គេហទំព័រ៖ www.mme.gov.kh
ទំព័រហ្វេសប៊ុក៖ Ministry of Mines and Energy Cambodia
បណ្តាញតេលេក្រាម៖ ក្រសួងរ៉ែ និងថាមពល-Ministry of Mine and Energy